ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ
For purchase information please visit
www.cambodianchristianresources.com/dfd

# ការដើរជាមួយព្រះគ្រីស្ទ

គម្រោងនៃការបង្កើតសិស្ស

## គបសព

NavPress
Discipleship Inside Out®

សហគមកម្ពុជា
www.smcambodia.org

NAVPRESS
Discipleship Inside Out®

NavPress គឺជាព័ន្ធកិច្ចនៃការបោះពុម្ពរបស់ The Navigators ដែលជាអង្គការគ្រីស្ទបរិស័ទអន្តរជាតិ ហើយជាអង្គការដែលឈានមុខគេខាងការអភិវឌ្ឍផ្នែកព្រលឹងវិញ្ញាណរបស់មនុស្ស។ NavPress បានប្តេជ្ញាចិត្តក្នុងការជួយមនុស្សឲ្យមានការលូតលាស់ផ្នែកព្រលឹងវិញ្ញាណ ហើយឲ្យមានអំណរទៅនឹងជីវិតដ៏មានន័យ ព្រមទាំងឲ្យមានសង្ឃឹមតាមរយៈធនធាននៃការសិក្សាផ្ទាល់ខ្លួន ឬការសិក្សាជាក្រុមដែលក្រុម The Navigators បាននិពន្ធ ពីព្រោះមូលដ្ឋានគ្រឹះនៃធនធានទាំងនេះបានដកស្រង់ចេញពីព្រះគម្ពីរ ហើយក៏ផ្តល់ភាពងាយស្រួលក្នុងការអនុវត្តដល់វប្បធម៌ផ្សេងៗទៀតផងដែរ។

បកប្រែដោយ៖ បេសកកម្មសាឡូមកម្ពុជា និង សកម្មភាពកម្ពុជា
Translated by: Shalom Mission Cambodia - http://www.smcambodia.org
and ACTION Cambodia - http://www.actioncambodia.org

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោកគ្រូ សាំង ឈិនហូរ, លោកគ្រូ ហុង សុភក្តិ, លោក ជួប ប៊ុនហាក់,
លោក ផេង វណ្ណៈ, លោក ឈាង ប៉ូវ៉ា, លោក ម៉ែន ជំនោ និង សកម្មភាពកម្ពុជា

សូមថ្លែងអំណរអរគុណដល់ លោក គឹម សីហា, លោក មាស ម៉ាដែស, លោក សួន សាយ័ន្ត,
អ្នកស្រី ឆាយ សូដាលីន និង កញ្ញា សុគន្ធ ចិន្តាមណី ដែលមានចំណែកក្នុងការអភិវឌ្ឍសៀវភៅនេះ។

ក្រុមយើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ឆ្នាំ១៩៥៤ ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូល យើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។
ព្រមជាមួយនឹងការប្រើប្រាស់កម្មវិធីត្រួតពិនិត្យអក្ខរាវិរុទ្ធ
និងវេយ្យាករណ៍ យូនីកូដខ្មែរ របស់ ស.ស.ឈ.ន.ក.
Using the SBBIC Unicode Khmer Spelling Checker
and Grammar Checker - http://www.sbbic.org

© 1973, 1980, 2006, 2013 by The Navigators
រក្សាសិទ្ធិគ្រប់យ៉ាង © ១៩៧៣, ១៩៨០, ២០០៦, ២០១៣ ដោយ The Navigators
All rights reserved. No part of this publication may be reproduced in any form without written permission from NavPress, P.O. Box 35001, Colorado Springs, CO 80935.
www.navpress.com

NAVPRESS and the NAVPRESS logo are registered trademarks of NavPress. Absence of ® in connection with marks of NavPress or other parties does not indicate an absence of registration of those marks.

ISBN 978-0-9890481-2-5

Cover design by Arvid Wallen
Cover illustration by Michael Halbert
Interior design by The DesignWorks Group
វចនាអត្ថបទភាសាខ្មែរ ៖ លោក សេង ធា និង លោក ម៉ែន ជំនោ
Creative Team: Dan Rich, Kathy Mosier, Arvid Wallen, Pamela Poll, Pat Reinheimer, Kathy Guist
Original DFD Author: Chuck Broughton
Revision Team: Dennis Stokes, Judy Gomoll, Christine Weddle, Ralph Ennis
អត្ថបទគម្ពីរ © រក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល-ដកស្រង់ដោយមានការអនុញ្ញាត
Printed in Cambodia

# គបស៣ | មាតិកា


របៀបទាញយកប្រយោជន៍ពីការសិក្សា ៥

ជំពូកទី១
ការលូតលាស់ក្នុងព្រះគ្រីស្ទ ៧

ជំពូកទី២
ភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទ ២៩

ជំពូកទី៣
ជំនឿនិងសេចក្តីសន្យារបស់ព្រះជាម្ចាស់ ៤៩

ជំពូកទី៤
ការស្គាល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ៧១

ជំពូកទី៥
ការដើរក្នុងនាមជាអ្នកបម្រើ ៩៥

# រៀបទាញយកប្រយោជន៍ពីការសិក្សា

ព្រះគម្ពីរគឺជាសៀវភៅនៃជីវិត និងជារតនសម្បត្តិនៃសេចក្តីពិតសម្រាប់ជីវិតរស់នៅឲ្យបានត្រឹមត្រូវ។ កណ្ឌគម្ពីរ ទំនុកដំកើង ១៩:៧-១១ បានប្រាប់យើងថា ព្រះគម្ពីរ៖

- ក៏កែព្រលឹងឡើងវិញ
- ក៏ធ្វើឲ្យមនុស្សខ្លៅល្ងង់មានប្រាជ្ញា
- ក៏បណ្តាលឲ្យចិត្តរីករាយសប្បាយ
- ក៏បំភ្លឺភ្នែក
- គួរចង់បានលើសជាងមាស
- ក៏ផ្អែមជាងទឹកឃ្មុំ
- ហើយដែលកាន់តាម នោះក៏មានរង្វាន់យ៉ាងធំ

ព្រះជាម្ចាស់បានប្រទានប្រាជ្ញាជាច្រើនក្នុងព្រះបន្ទូលរបស់ទ្រង់ ប្រៀបដូចជាទ្រព្យសម្បត្តិដែលគ្រប់ទាំងអ្នកជឿអាចស្វែងរកបាន។ ប៉ុន្តែដើម្បីឲ្យអាចទទួលបាន លុះត្រាតែពួកគេខំប្រឹងប្រែងដោយខ្លួនគេផ្ទាល់។ ការបើកចំហចិត្ត ការសញ្ជឹងគិត និងការអធិស្ឋាន គឺជាកូនសោរដែលអាចបើកទ្វារនៃប្រាជ្ញារបស់ព្រះជាម្ចាស់នៅពេលដែលលោកអ្នកសិក្សា។ ខណៈពេលដែលលោកអ្នកអាន

ខគម្ពីរនីមួយៗក្នុងវគ្គសិក្សានេះ សូមចំណាយពេលខ្លះ ដើម្បីសញ្ជឹងគិតលើខគម្ពីរទាំងនោះដោយការអធិស្ឋាន។ ការធ្វើបែបនេះនឹងជួយលោកអ្នកឲ្យយល់នូវអត្ថន័យពីខគម្ពីរទាំងនោះ ហើយជួយលោកអ្នកឲ្យអាចស្ដាប់តាមព្រះបន្ទូលរបស់ទ្រង់ក្នុងជីវិតរស់នៅរបស់លោកអ្នក។ ក្នុងវគ្គសិក្សានៃសៀវភៅ “ការដើរជាមួយព្រះគ្រីស្ទ” នេះ លោកអ្នកនឹងរៀនពីចំណុចសំខាន់ៗប្រាំយ៉ាងនៃជីវិតដែលនៅជាប់ជាមួយទ្រង់៖

- ការលូតលាស់ក្នុងព្រះគ្រីស្ទ
- ភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទ
- ជំនឿនិងសេចក្ដីសន្យារបស់ព្រះជាម្ចាស់
- ការស្គាល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់
- ការដើរក្នុងនាមជាអ្នកបម្រើ

ជំពូកទី

# ១

# ការលូតលាស់ក្នុងព្រះគ្រីស្ទ

ពិភពលោកសព្វថ្ងៃ គឺពោរពេញទៅដោយការច្នៃប្រឌិតដែលអាចបំពេញតម្រូវការរបស់មនុស្សបានយ៉ាងឆាប់រហ័ស និងងាយស្រួលបំផុតដូចជាៈ អាហារទាន់ចិត្ត ទំនាក់ទំនងខាងបច្ចេកវិទ្យាយ៉ាងរហ័ស ព័ត៌មានទទួលបានទាន់ហេតុការណ៍តាមរយៈប្រព័ន្ធអ៊ីនធឺណិតជាដើម។ ទោះបីជាយ៉ាងណាក៏ដោយ យើងត្រូវតែចងចាំថា គ្មាន “ការលូតលាស់យ៉ាងរហ័ស” ក្នុងព្រះគ្រីស្ទនោះឡើយ។ ការដែលយើងក្លាយជាអ្នកជឿម្នាក់ នោះគឺជាការចាប់ផ្តើមក្នុងការស្គាល់ព្រះជាម្ចាស់កាន់តែច្បាស់ឡើង កាន់តែស្រឡាញ់ទ្រង់ឡើង ហើយក៏ផ្លាស់ប្រែកាន់តែដូចព្រះគ្រីស្ទឡើងផងដែរ គឺប្រៀបដូចជាដំណើរជីវិតផ្សងព្រេងក្នុងព្រះជាម្ចាស់អញ្ចឹង។

កុំឲ្យត្រាប់តាមសម័យនេះឡើយ ចូរឲ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង ដើម្បីនឹងអាចលមើលឲ្យបានស្គាល់បំណងព្រះហឫទ័យនៃព្រះ ដែលល្អ ស្រួលទទួល ហើយគ្រប់លក្ខណ៍ផង (រ៉ូម ១២:២)។

# ចំណុចចាប់ផ្តើមរបស់លោកអ្នក



១. សូមអានកណ្ឌគម្ពីរ កូល៉ុស ២:៦-៧។ តើលោកអ្នកបានចាប់ផ្តើមជីវិតនៅក្នុងព្រះគ្រីស្ទយ៉ាងដូចម្តេច?

តើលោកអ្នកគួរតែបន្ត ដើម្បីឲ្យមានការរីកចម្រើនយ៉ាងដូចម្តេច?

២. សូមពិចារណាលើកណ្ឌគម្ពីររ៉ូម ៥:១-៥។ ដោយសារព្រះជាម្ចាស់បានរាប់លោកអ្នកជាសុចរិតតាមរយៈជំនឿក្នុងព្រះគ្រីស្ទ តើមានគុណប្រយោជន៍ជាក់ស្ដែងណាខ្លះ ដែលលោកអ្នកទទួលបាន?

ហេតុអ្វីបានជាគុណប្រយោជន៍នេះអាចផ្តល់ក្តីសង្ឃឹមដល់លោកអ្នក?

៣. សូមអានកណ្ឌគម្ពីរ អេភេសូរ ១:១-១៤ ហើយសូមសរសេរចុះពីលទ្ធផលមួយចំនួនដែលលោកអ្នកបានទទួលដោយសារលោកអ្នកនៅក្នុងព្រះគ្រីស្ទ?

៤. លោកអ្នកបានចាប់ផ្ដើមបោះជំហានដំបូងឆ្ពោះទៅរកភាពពេញវ័យខាងឯវិញ្ញាណ នៅពេលដែលលោកអ្នកដាក់ជំនឿក្នុងព្រះគ្រីស្ទ។ សូមសរសេរចុះពីចំណុចសំខាន់ៗនៃដំណឹងល្អស្ដីពីព្រះបន្ទូលដែលលោកអ្នកបានជឿដោយភ្ជាប់មកជាមួយនឹងខគម្ពីរយោងសម្រាប់ចំណុចនីមួយៗទាំងនោះផង។

# ដំណើរឆ្ពោះទៅរកភាពពេញវ័យ



៥. សូមអានកណ្ឌគម្ពីរ អេភេសូរ ៤:១១-១៦។

ក) តើព្រះជាម្ចាស់មានព្រះហឫទ័យយ៉ាងដូចម្តេចសម្រាប់លោកអ្នក? (ខ១៣, ១៥)

ខ) តើអ្នកជឿដែលពុំទាន់ពេញវ័យខាងវិញ្ញាណដែលប្រៀបបានទៅនឹងកូនតូចក្នុងខ១៤ មានចរិតលក្ខណៈបែបណា?

គ) យោងទៅតាមអត្ថបទខាងលើនេះ តើមនុស្សពេញវ័យខាងវិញ្ញាណមានចរិតលក្ខណៈយ៉ាងដូចម្តេច?

ឃ) តើមានផ្នែកណាខ្លះដែលអ្នកដទៃផ្សេងទៀតអាចរួមចំណែកក្នុងភាពពេញវ័យរបស់យើងបាន? (សូមអាន ហេព្រើរ ៣:១៣ និង អេភេសូរ ៥:១៩-២១)

៦. ចូរប្រៀបធៀបពីភាពផ្ទុយគ្នារវាងនិស្ស័យចាស់ ទៅនឹងនិស្ស័យថ្មីរបស់អ្នកជឿ (អេភេសូរ ៤:២២-២៤)។

| និស្ស័យចាស់ | និស្ស័យថ្មី |
|---|---|
| | |

៧. សូមពិចារណាលើកណ្ឌគម្ពីរ ២កូរិនថូស ៣:១៨។

ក) តើលោកអ្នកកំពុងតែផ្លាស់ប្រែទៅក្នុងរូបអង្គរបស់អ្នកណា?

ខ) តើនរណាដែលនាំឲ្យមានការផ្លាស់ប្រែនេះ?

គ) តើលោកអ្នកបានទទួលការផ្លាស់ប្រែគ្រប់ការទាំងអស់យ៉ាងពេញលេញក្នុងពេលតែមួយឬ? សូមពន្យល់៖

៨. តើខគម្ពីរខាងក្រោមនេះ ប្រាប់ពីទំនាក់ទំនងរបស់លោកអ្នកជាមួយព្រះគ្រីស្ទយ៉ាងដូចម្ដេចខ្លះ?

ក) តើមានអ្វីដែលបានកើតឡើងចំពោះលោកអ្នករួចហើយ? (រ៉ូម ៥:៨-៩)

ខ) តើឥឡូវនេះ លោកអ្នកគួរតែធ្វើអ្វី? (រ៉ូម ៦:១៩)

គ) តើលោកអ្នករំពឹងថានឹងទទួលបានអ្វីនៅពេលអនាគត? (រ៉ូម ៨:១៦-១៨)

ទស្សនៈបីយ៉ាងនៃសេចក្តីសង្គ្រោះក្នុងព្រះគ្រីស្ទដែលអាចជួយអ្នកជឿឲ្យយល់ពីផែនការរបស់ព្រះជាម្ចាស់៖

| | | |
|---|---|---|
| ការរាប់ជាសុចរិត | អតីតកាល-ខ្ញុំបានសង្គ្រោះ...រួចពីទណ្ឌកម្មនៃបាប | ជំហរខ្ញុំនៅក្នុងព្រះគ្រីស្ទ |
| ការញែកជាបរិសុទ្ធ ការផ្លាស់ប្រែ | បច្ចុប្បន្នកាល-ខ្ញុំកំពុងតែបានសង្គ្រោះ...រួចពីអំណាចនៃបាប | ស្ថានភាពរបស់ខ្ញុំគឺកំពុងតែប្រែក្លាយកាន់តែដូចជាព្រះគ្រីស្ទ |
| ការប្រទានសិរីល្អ | អនាគតកាល-ខ្ញុំនឹងបានសង្គ្រោះ...រួចពីវត្តមាននៃបាប | ក្តីរំពឹងរបស់ខ្ញុំគឺឲ្យបានដូចជាព្រះគ្រីស្ទ |

នៅពេលដែលលោកអ្នកសម្លឹងមើលទៅសេចក្តីសង្គ្រោះរបស់លោកអ្នកកាលពីអតីតកាល ពេលបច្ចុប្បន្ន និងនាពេលអនាគតដែលមានបញ្ជាក់នៅក្នុងតារាងខាងលើនេះ តើការនេះផ្តល់សេចក្តីសង្ឃឹមដល់លោកអ្នកយ៉ាងដូចម្តេច?

៩. សូមពិចារណាដោយយកចិត្តទុកដាក់ទៅលើកណ្ឌគម្ពីរ កូល៉ុស ៣:២-៤។ តើខគម្ពីរទាំងនេះជាប់ទាក់ទងនឹងតារាងខាងលើយ៉ាងដូចម្តេច?

# ដំណើរនៃការលូតលាស់



១០. ជីវិតខាងរូបកាយ និងជីវិតខាងវិញ្ញាណ
មានលក្ខណៈស្រដៀងគ្នាជាច្រើន។
តើខគម្ពីរខាងក្រោមនេះបានបញ្ជាក់ពីភាព
ស្រដៀងគ្នារវាងជីវិតខាងរូបកាយ និងជីវិតខាងវិញ្ញាណយ៉ាងដូចម្ដេច?
១ថែស្សាឡូនីច ២:១១

១ធីម៉ូថេ ៤:៨

១ពេត្រុស ២:២-៣

សូមសរសេរពីភាពស្រដៀងគ្នាមួយផ្សេងទៀតដែលទាក់ទងទៅនឹង
ការលូតលាស់ខាងរូបកាយ និងការលូតលាស់ខាងព្រលឹងវិញ្ញាណ
តាមបទពិសោធន៍ ឬក៏តាមការសង្កេតរបស់លោកអ្នក។

១១. សូមសញ្ជឹងគិតលើកណ្ឌគម្ពីរ រ៉ូម ៦:១១-១៣។

ក) តើលោកអ្នកគួររាប់ខ្លួនរបស់លោកអ្នកយ៉ាងដូចម្ដេច? (ខ១១)

ខ) តើបច្ចុប្បន្ននេះលោកអ្នកគួរមានទំនាក់ទំនងជាមួយអំពើបាបយ៉ាង ដូចម្ដេច? (ខ១២)

គ) តើអ្វីដែលលោកអ្នកមិនត្រូវអនុញ្ញាតឲ្យកើតមានឡើង? (ខ១៣)

ឃ) តើទង្វើបែបណាដែលលោកអ្នកគួរធ្វើ? (ខ១៣)

ង) សូមពន្យល់អំពីសេចក្ដីពិតនៃកណ្ឌគម្ពីរ រ៉ូម ៦:៥-៦ តាមគំនិតផ្ទាល់ ខ្លួនរបស់លោកអ្នក។

១២. ព្រះជាម្ចាស់មានព្រះហឫទ័យឲ្យព្រះយេស៊ូវគ្រីស្ទសោយរាជ្យក្នុងជីវិតរបស់លោកអ្នកផ្ទាល់ (រ៉ូម ៥:១៧) មិនមែនឲ្យបាបសោយរាជ្យក្នុងជីវិតលោកអ្នកនោះឡើយ (រ៉ូម ៦:១២)។ តើលោកអ្នកអាចយកខគម្ពីរទាំងនេះមកអនុវត្តក្នុងជីវិតផ្ទាល់ខ្លួនបានយ៉ាងដូចម្ដេច?

១៣. សាវ័ក ប៉ុល មានប្រសាសន៍ថា អ្នកជឿគ្រប់រូបបានទទួលសេចក្ដីសង្គ្រោះដោយសារជំនឿ (អេភេសូរ ២:៨-៩) ប៉ុន្តែទំនាក់ទំនងរបស់លោកអ្នកជាមួយព្រះជាម្ចាស់មិនមែនចប់ត្រឹមនេះនោះទេ។

ក) តើកណ្ឌគម្ពីរ អេភេសូរ ២:១០ បានបង្ហាញថាលោកអ្នកជាអ្វី?

ខ) តើព្រះជាម្ចាស់បង្កើតលោកអ្នកមក ដើម្បីធ្វើកិច្ចការអ្វី?

គ) តើព្រះជាម្ចាស់កំពុងតែធ្វើអ្វី? (ភីលីព ១:៦)

ឃ) តើលោកអ្នកគិតថា ផ្នែកមួយណានៅក្នុងជីវិតរបស់លោកអ្នកដែលព្រះជាម្ចាស់កំពុងតែកែតម្រង់នាពេលសព្វថ្ងៃនេះ?

> “ ខ្ញុំសួរមកខ្លួនឯងថា ប្រសិនបើខ្ញុំមើលឃើញអត្តសញ្ញាណសំខាន់ក្នុងជីវិតរបស់ខ្ញុំជា “មនុស្សម្នាក់ដែលព្រះយេស៊ូវស្រឡាញ់” នោះ តើវាមានន័យយ៉ាងណា? នៅទីបញ្ចប់ តើខ្ញុំនឹងគិតទៅលើខ្លួនឯងខុសប្លែកពីមុនយ៉ាងណា?
>
> លោក ភីលីព យេនស៊ី (Philip Yancey)
> ដកស្រង់ចេញពីសៀវភៅ *What's So Amazing About Grace?*

## ផ្អាកបន្តិចដើម្បីអធិស្ឋាន

បុគ្គលភាពខាងក្រៅរបស់យើងគ្រាន់តែជាគ្រោងរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ឯរូបដ៏ពិតប្រាកដនោះគឺបុគ្គលភាពខាងក្នុងដែលព្រះជាម្ចាស់ដ៏ជាវិចិត្រករកំពុងតែបង្កើតឡើង។ ខណៈពេលដែលលោកអ្នកគិតទៅលើជីវិត ចូរអរព្រះគុណចំពោះការទាំងអស់ដែលព្រះជាម្ចាស់កំពុងតែធ្វើនៅក្នុងជីវិតរបស់លោកអ្នក។ ការតយុទ្ធផ្សេងៗនៅក្នុងជីវិតលោកអ្នកគួរតែជាការលើកទឹកចិត្តដល់លោកអ្នក ពីព្រោះវាបានបង្ហាញថា ព្រះជាម្ចាស់កំពុងតែកែតម្រង់លោកអ្នក ដើម្បីបំផ្លាស់បំប្រែលោកអ្នកឲ្យបានដូចជាព្រះគ្រីស្ទ។ សូមចំណាយពេលបន្តិចដើម្បីអរព្រះគុណដល់ព្រះជាម្ចាស់ចំពោះការដែលទ្រង់បានធ្វើ ទាំងការដែលទ្រង់កំពុងតែធ្វើ និងការដែលទ្រង់នឹងធ្វើសម្រាប់លោកអ្នក។

# របៀបក្នុងការរស់នៅ



១៤. សូមមើលកណ្ឌគម្ពីរ ១យ៉ូហាន ១:៦-១០ រួចសរសេរពីភាពផ្ទុយគ្នារវាងអ្នកដែលដើរក្នុងសេចក្ដីប្រកបជាមួយព្រះជាម្ចាស់ និងអ្នកដែលមិនដើរក្នុងសេចក្ដីប្រកបជាមួយព្រះជាម្ចាស់។

| អ្នកដែលដើរក្នុងសេចក្ដីប្រកបជាមួយព្រះជាម្ចាស់ | អ្នកដែលមិនដើរក្នុងសេចក្ដីប្រកបជាមួយព្រះជាម្ចាស់ |
|---|---|
| | |

១៥. សូមអានកណ្ឌគម្ពីរ ហេព្រើរ ៥:១៣-១៤។

ក) តើអ្នកជឿដែលមានភាពពេញវ័យមានលក្ខណៈយ៉ាងដូចម្ដេច?

ខ) តើលោកអ្នកបានជួបប្រទះការល្អ និងការអាក្រក់នៅក្នុងជីវិតប្រចាំថ្ងៃតាមរបៀបណាខ្លះ?

គ) នៅពេលដែលលោកអ្នកប្រឈមមុខនឹងការអាក្រក់ ជាធម្មតា តើលោកអ្នកនឹងសម្រេចចិត្តថា ឲ្យសេចក្ដីយុត្តិធម៌ឈ្នះ ឬក៏ឲ្យសេចក្ដីមេត្តាឈ្នះ? (យ៉ាកុប ២:១២-១៣)

“ *គ្រីស្ទបរិស័ទពេញវ័យជាច្រើនដែលខ្ញុំបានជួបជាហូរហែមកនោះ គឺជាអ្នកដែលធ្លាប់បរាជ័យ ហើយរៀនរស់នៅជាមួយការបរាជ័យរបស់គេដោយសុភាពរាបសារ។ ភាពស្មោះត្រង់ទាមទារឲ្យមានចិត្តក្លាហានក្នុងការប្រថុយប្រថានគ្រប់បែបយ៉ាងទៅលើព្រះយេស៊ូវ និងទាមទារឲ្យយើងមានបំណងចិត្តចង់ ឲ្យមានការរីកចម្រើន ព្រមទាំងឲ្យយើងត្រៀមខ្លួនជាស្រេចក្នុងការប្រថុយប្រថានទៅនឹងការបរាជ័យក្នុងជីវិតរស់នៅរបស់យើង។*

លោក ប្រេនណែន ម៉ែននីង (Brennan Manning)
ដកស្រង់ចេញពីសៀវភៅ *Reflections for Ragamuffins*

១៦. តើអ្នកដើរតាមព្រះយេស៊ូវដែលមានភាពពេញវ័យខាងព្រលឹងវិញ្ញាណគួរតែមានគំនិតបែបណា? (ភីលីព ៣:១៣-១៥)



១៧. សូមអានកណ្ឌគម្ពីរ ១កូរិនថូស ១៥:៥៨។ ខណៈពេលដែលអ្នកជឿកំពុងទន្ទឹងរង់ចាំភាពអស់កល្បនៅជាមួយព្រះគ្រីស្ទ តើពួកគេគួរតែធ្វើអ្វីខ្លះ?

តើអ្វីជាការធានាអះអាងពីខគម្ពីរនេះដែលអាចជំរុញឲ្យលោកអ្នកធ្វើការនេះបាន?

១៨. តើមានផ្នែកណាខ្លះដែលលោកអ្នកអាចចម្រើនឡើងបានខាងឯវិញ្ញាណ?
១ធីម៉ូថេ ៤:១២

២ពេត្រុស ៣:១៨

១យ៉ូហាន ៤:១៦-១៧

១៩. នៅពេលជីវិតរបស់សាវ័ក ប៉ុល ជិតឈានដល់ដំណាក់កាលចុងក្រោយ គាត់បានសរសេរសំបុត្រមួយច្បាប់ទៅកាន់លោក ធីម៉ូថេ ដែលជាកូនប្រុសខាងឯជំនឿរបស់គាត់។ សូមអានកណ្ឌគម្ពីរ ២ធីម៉ូថេ ៤:៧-៨ បន្ទាប់មកសូមបញ្ជាក់ពីអ្វីដែលសាវ័ក ប៉ុល បានលើកឡើងស្ដីពីការដែលគាត់ដើរជាមួយព្រះគ្រីស្ទនៅលើផែនដីនេះ។

តើគាត់បានទទួលរង់ចាំអ្វីនៅថ្ងៃអនាគត?

## សំណើរខគម្ពីរមួយសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់



កូល៉ុស ២:៧

ដោយបានចាក់ឫស ហើយស្អាងឡើងក្នុងទ្រង់ ទាំងតាំងនៅខ្ជាប់ខ្ជួនក្នុងសេចក្ដីជំនឿ ដូចជាបានបង្រៀនដល់អ្នករាល់គ្នាហើយ ព្រមទាំងអរព្រះគុណកាន់តែច្រើនឡើងផង។

កូល៉ុស ២:៧

# សៀវភៅកំណត់ហេតុរបស់ខ្ញុំ

អស់រយៈពេលប្រាំមួយខែកន្លងមក តើលោកអ្នកបានលូតលាស់ផ្នែកត្រង់ណាខ្លះនៅក្នុងព្រះគ្រីស្ទ?

## ចំណុចគួរចងចាំ

- ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យអ្នកដើរតាមព្រះគ្រីស្ទមានភាពពេញវ័យឡើង ហើយឲ្យបានប្រែក្លាយដូចជាព្រះគ្រីស្ទ។ ព្រះជាម្ចាស់បានសង្គ្រោះរាស្ត្ររបស់ទ្រង់ឲ្យរួចផុតពីទណ្ឌកម្មនៃបាប។ ខណៈពេលដែលពួកគេរស់នៅលើផែនដីនៅឡើយ ពួកគេត្រូវតយុទ្ធជាមួយនឹងបាប ប៉ុន្តែពួកគេអាចស្មានទុកជាមុននៅថ្ងៃអនាគតថា ពួកគេនឹងគ្មានបាបទៀត ហើយរស់នៅជាមួយព្រះគ្រីស្ទក្នុងរូបកាយដែលពេញដោយសិរីល្អ។
- ជំនឿក្នុងព្រះគ្រីស្ទគឺជាចំណុចចាប់ផ្ដើមនៃការលូតលាស់ខាងវិញ្ញាណ។ អ្នកជឿទាំងឡាយសុទ្ធតែមានប្រភពមកពីព្រះជាម្ចាស់ជាស្រេច ដើម្បីឲ្យទ្រង់ជួយពួកគេឲ្យមានការលូតលាស់។
- ការលូតលាស់ខាងវិញ្ញាណក៏មានភាពស្រដៀងគ្នាទៅនឹងការលូតលាស់ខាងរាងកាយផងដែរ។ វាទាមទារនូវការចំណាយពេល ដើម្បីឲ្យព្រះជាម្ចាស់ធ្វើការក្នុងជីវិតអ្នកជឿគ្រប់ៗរូប។ អ្នកជឿគ្រប់ៗរូបគួរតែចេះគ្រប់គ្រងជីវិតរបស់ខ្លួនដោយទទួលស្គាល់ថា ព្រះជាម្ចាស់កំពុងនាំគេទៅបំពេញនូវកិច្ចការដែលទ្រង់បានចាប់ផ្ដើមក្នុងជីវិតពួកគេ។
- ការលូតលាស់នៅក្នុងព្រះគ្រីស្ទ គឺស្រដៀងគ្នាទៅនឹងការដែលយើងកំពុងដើរយ៉ាងដូច្នោះដែរ។ ព្រះវិញ្ញាណបរិសុទ្ធបានដឹកនាំអ្នកដើរតាមព្រះយេស៊ូវគ្រប់រូបឲ្យចេះដើរដោយជំនឿ ព្រមទាំងមានសេចក្ដីស្រឡាញ់ និងការប្រកបជាមួយព្រះគ្រីស្ទជានិច្ច។

- អ្នកជឿដែលពេញវ័យ គឺជាអ្នកដែលបន្តដំណើរដើរតាមព្រះគ្រីស្ទ ដោយបម្រើទ្រង់យ៉ាងស្មោះត្រង់ ហើយបានពិសោធពីព្រះគុណ និងសេចក្ដីស្រឡាញ់របស់ទ្រង់។ ព្រះជាម្ចាស់មិនដែលបំភ្លេចរាល់កិច្ចការរបស់អ្នកជឿនោះឡើយ ហើយថ្ងៃណាមួយពួកគេនឹងបានទទួលរង្វាន់ជាក់ជាមិនខាន។



## ការចូលឲ្យបានស៊ីជម្រៅ

សូមសរសេរឈ្មោះអ្នកជឿមួយចំនួនដែលលោកអ្នកស្គាល់ជិតដិត ហើយចាត់ទុកពួកគេជាអ្នកពេញវ័យខាងឯវិញ្ញាណ។ បន្ទាប់មកទូរស័ព្ទទៅកាន់ពួកគេ ផ្ញើអ៊ីមែលទៅពួកគេ ឬក៏ចុះទៅសួរសុខទុក្ខអ្នកណាម្នាក់ក្នុងចំណោមពួកគេទាំងនោះ។ សូមសួរសំណួរខាងក្រោមនេះ ហើយសរសេរចម្លើយរបស់ពួកគេ៖

តើព្រះជាម្ចាស់បានប្រើអ្វីខ្លះ ដើម្បីឲ្យលោកអ្នករីកចម្រើនខាងឯវិញ្ញាណ?

តើលោកអ្នករៀនបានអ្វីខ្លះ ក្នុងកំឡុងពេលនៃដំណើរទៅកាន់ភាពពេញវ័យខាងឯវិញ្ញាណរបស់លោកអ្នក?

សំណួរផ្សេងៗទៀត?

ជំពូកទី

# ២

# ភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទ

ព្រះយេស៊ូវគ្រីស្ទជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់ ទ្រង់មិនមែនត្រឹមតែជាព្រះនៃអ្នកដើរតាមទ្រង់តែប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ជាព្រះលើសអស់ទាំងព្រះ។ មនុស្សទាំងអស់នៅលើផែនដីនេះមិនមែនសុទ្ធតែទទួលស្គាល់ទ្រង់ទុកជាព្រះអម្ចាស់របស់ពួកគេនោះទេ ប៉ុន្តែទោះបីជាពួកគេមិនទទួលស្គាល់ទ្រង់ក៏ដោយ ក៏ព្រះយេស៊ូវ នៅតែជាព្រះអម្ចាស់ដដែល ហើយនៅពេលដែលព្រះយេស៊ូវគ្រីស្ទយាងមកជាលើកទី២ មនុស្សទាំងអស់នឹងទទួលស្គាល់ថាព្រះគ្រីស្ទគឺជាព្រះអម្ចាស់ពិតមែន។ មុនពេលនោះមកដល់ អស់អ្នកណាដែលទុកចិត្តទ្រង់ពេញទី នោះនឹងទទួលបានអភ័យឯកសិទ្ធិក្នុងការស្តាប់បង្គាប់ព្រះអម្ចាស់ និងចូលទៅក្នុងឥទ្ធិពលរបស់ព្រះគ្រីស្ទផងដែរ។ ដើម្បីឲ្យព្រះគ្រីស្ទធ្វើជាព្រះអម្ចាស់របស់យើង ជាដំបូងយើងត្រូវសម្រេចចិត្តជឿទុកចិត្តទ្រង់ ហើយបន្ទាប់មកយើងត្រូវអនុវត្តជាប់ជាប្រចាំជាមួយនឹងបំណងចិត្តនៃការស្តាប់បង្គាប់ទ្រង់។

ស្ថិតនៅក្រោមការដឹកនាំរបស់ព្រះគ្រីស្ទ យើងអាចទទួលបាននូវទំនុកចិត្តយ៉ាងពេញលេញនៅក្នុងការការពារដែលពេញដោយសេចក្តីស្រឡាញ់របស់ទ្រង់។

## ព្រះអម្ចាស់យេស៊ូវគ្រីស្ទ



១. មានងារជាច្រើនបានបង្ហាញឲ្យឃើញពីលក្ខណៈដ៏សំខាន់ៗស្តីអំពីបុគ្គលម្នាក់ដែលគេសំដៅទៅលើនោះ។
តើព្រះយេស៊ូវគ្រីស្ទមានងារអ្វីខ្លះនៅខគម្ពីរខាងក្រោមនេះ?
យ៉ូហាន ១៣:១៣

កិច្ចការ ២:៣៦

វិវរណៈ ១៩:១៦

សូមសង្ខេបពីងាររបស់ព្រះយេស៊ូវដែលបានបង្ហាញក្នុងខគម្ពីរខាងលើ។

២. តើព្រះយេស៊ូវគ្រីស្ទគឺជាព្រះអម្ចាស់នៃអ្វី និងរបស់អ្នកណា? (សូមភ្ជាប់ចម្លើយខាងក្រោមជាមួយនឹងខយោងឲ្យបានត្រឹមត្រូវ)៖

| | |
|---|---|
| ការបង្កើត | កូល៉ុស ១:១៦-១៧ |
| មនុស្សរស់ និងមនុស្សស្លាប់ | កូល៉ុស ១:១៨ |
| គ្រប់អ្នកជឿ-ពួកជំនុំ | រ៉ូម ១៤:៩ |

៣. សូមសរសេរនូវនិយមន័យនៃពាក្យ “ព្រះអម្ចាស់” តាមគំនិតលោកអ្នកដែលសំដៅទៅលើព្រះយេស៊ូវគ្រីស្ទ (វចនានុក្រមអាចជាឧបករណ៍ក្នុងការជួយផ្ដល់នូវគំនិតមួយចំនួនដល់លោកអ្នកបាន)។

៤. សូមអានកណ្ឌគម្ពីរ ភីលីព ២:៩-១១។

ក) តើព្រះជាម្ចាស់បានលើកតម្កើងព្រះយេស៊ូវយ៉ាងដូចម្ដេច?

ខ) តើមនុស្សគ្រប់រូបនឹងលើកតម្កើងទ្រង់យ៉ាងដូចម្ដេច?

៥. តើពួកទេវតាបានទទួលស្គាល់ពីភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទនៅក្នុង
កណ្ឌគម្ពីរ វិវរណៈ ៥:១១-១២ យ៉ាងដូចម្ដេច?

៦. សូមអានកណ្ឌគម្ពីរ ១កូរិនថូស ៦:១៩-២០។

ក) តើលោកអ្នកបានក្លាយជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ដោយរបៀបណា?

ខ) ដោយសារតែការនេះ តើលោកអ្នកគួរធ្វើអ្វីខ្លះ?

គ) តើលោកអ្នកមានអារម្មណ៍ដូចម្ដេចអំពីការរស់នៅជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់?

## ការទទួលស្គាល់ភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទតាមរយៈការសម្រេចចិត្ត



ព្រះគ្រីស្ទគួរតែគង់នៅជាដរាបក្នុងចិត្តរបស់យើង ដូចដែលទ្រង់គ្រប់គ្រងលើសកលលោកយ៉ាងដូច្នោះដែរ។

៧. តើព្រះយេស៊ូវគួរមានឋានៈជាអ្វីក្នុងជីវិតរបស់អ្នកជឿ? (កូល៉ុស ១:១៨)

តើលោកអ្នកយល់ថា ការដែលព្រះយេស៊ូវគង់នៅកន្លែងជដែលក្នុងចិត្ត របស់យើងដូចដែលទ្រង់គ្រប់គ្រងលើសកលលោកនោះមានលក្ខណៈ ដូចម្តេចដែរ?

៨. តើនៅក្នុងកណ្ឌគម្ពីរ រ៉ូម ១២:១ បានតម្រូវឲ្យយើងធ្វើអ្វីខ្លះ?

ហេតុអ្វីបានជាយើងគួរធ្វើការនេះ?

៩. សូមគូសសញ្ញាគ្រីស (✓) លើប្រយោគណាដែលលោកអ្នកធ្លាប់មាន អារម្មណ៍ដូចប្រយោគខាងក្រោមនេះ៖

__ព្រះយេស៊ូវពិតជាមិនយល់ពីបញ្ហារបស់ខ្ញុំទេ។

__ប្រហែលជាទ្រង់ចង់ឲ្យខ្ញុំធ្វើអ្វីដែលខ្ញុំមិនអាចធ្វើបាន។

__ប្រហែលជាទ្រង់ចង់ឲ្យខ្ញុំធ្វើការដែលខ្ញុំមិនចូលចិត្ត។

__ ទ្រង់បានធ្វើឲ្យខ្ញុំបរាជ័យបាត់ទៅហើយ។

__ ទ្រង់នឹងរារាំងមិនឲ្យខ្ញុំរៀបការ។

__ ទ្រង់នឹងដកឯកសិទ្ធិនៃភាពសប្បាយរីករាយ ចំណង់ចំណូលចិត្ត ឬមិត្រសម្លាញ់របស់ខ្ញុំចេញពីខ្ញុំជាមិនខាន។

__ ទ្រង់អាចជួយខ្ញុំគ្រប់ការធំៗទាំងប៉ុន្មាន ប៉ុន្តែទ្រង់មិនខ្វល់ពីការតូចៗទេ។

តើមានសេចក្តីភ័យខ្លាចណាខ្លះដែលបានរារាំងលោកអ្នកពីការអនុញ្ញាតឲ្យព្រះគ្រីស្ទចូលទៅក្នុងគ្រប់ទាំងផ្នែកនៃជីវិតរបស់លោកអ្នក?

តើការបើកបង្ហាញពីទឹកព្រះទ័យរបស់ព្រះជាម្ចាស់នៅក្នុងកណ្ឌគម្ពីរយេរេមា ២៩:១១ ធ្វើឲ្យភាពភ័យខ្លាចទាំងអស់នេះរលាយបាត់ទៅយ៉ាងដូចម្តេច?

១០. សូមពិចារណាលើសម្រង់សម្ដីខាងក្រោមនេះដោយប្រៀបធៀបពីការឲ្យព្រះយេស៊ូវធ្វើជាព្រះអម្ចាស់របស់យើង ជាមួយនឹងការឲ្យកូនកំលោះធ្វើជាម្ចាស់ដួងចិត្តរបស់កូនក្រមុំ។ តើមានភាពប្រហាក់ប្រហែលគ្នាណាខ្លះដែលលោកអ្នកបានឃើញរវាងកូនក្រមុំដែលស្ម័គ្រចិត្តប្រគល់រូបកាយដល់កូនកំលោះរបស់នាងដោយសេចក្ដីស្រឡាញ់ ហើយរស់នៅដោយជឿទុកចិត្តលើគាត់ ធៀបទៅនឹងអស់អ្នកជឿដែលបានប្រគល់ជីវិតរបស់ពួកគេឲ្យទៅព្រះគ្រីស្ទពេញដោយសេចក្ដីស្រឡាញ់ដ៏យូរអង្វែង ហើយរស់នៅដោយជឿទុកចិត្តលើទ្រង់។

> *ដើម្បីទទួលស្គាល់ពីភាពជាព្រះអម្ចាស់របស់ទ្រង់ យើងត្រូវមានការជ្រើសរើសដែលច្បាស់លាស់តាមឆន្ទៈរបស់ខ្លួន ពីព្រោះទ្រង់ត្រូវធ្វើជាព្រះអម្ចាស់លើអ្វីៗទាំងអស់។ ឧទាហរណ៍៖ នៅពេលដែលកូនក្រមុំព្រមព្រៀងតាមការផ្សំផ្គុំរបស់មាតាបិតាទាំងសងខាងរួចហើយ នោះនាងនឹងអនុញ្ញាតឲ្យកូនកំលោះធ្វើជាម្ចាស់ដួងចិត្តរបស់នាងជារៀងរហូត។ ក្នុងរយៈពេលក្រោយមកទៀត នាងនឹងត្រូវរស់នៅដោយបង្ហាញពីទង្វើល្អដល់ប្ដីរបស់ខ្លួន ចាប់តាំងពីវិនាទីនៃការសម្រេចចិត្តធ្វើតាមការផ្សំផ្គុំរបស់ឪពុកម្ដាយទាំងសងខាង។ ដូចគ្នានេះដែរ ការដែលយើងយាងព្រះគ្រីស្ទមកធ្វើជាម្ចាស់ជីវិតរបស់យើង មានលក្ខណៈដូចទៅនឹងការដែលយើងសម្រេចចិត្តឲ្យកូនកំលោះធ្វើជាម្ចាស់ដួងចិត្តរបស់យើងដូច្នេះដែរ ព្រោះកាលណាដែលយើងយាងព្រះគ្រីស្ទធ្វើជាម្ចាស់ជីវិតហើយ នោះមានន័យថា យើងត្រូវលះបង់ភាពជាម្ចាស់លើខ្លួនឯងរួចចុះចូលចំពោះទ្រង់វិញ។*
>
> លោក ជេ. អស្វលដ៍ សានដឺរ (J. Oswald Sanders)*

* មកពី J. Oswald Sanders, *The Pursuit of the Holy* (Grand Rapids, MI: Zondervan, ឆ្នាំ១៩៧២), ទំព័រ៦៥។

ក) តើមានអ្វីដែលធ្វើឲ្យលោកអ្នកមានចិត្តរំភើបចង់ចុះចូលចំពោះព្រះគ្រីស្ទដូចដែលកូនក្រមុំបានចុះចូលចំពោះប្ដីរបស់នាង?

ខ) តើមានចំណុចអ្វីខ្លះដែលបំភ័យលោកអ្នកឲ្យចុះចូលចំពោះការគ្រប់គ្រងរបស់ព្រះគ្រីស្ទ?

១១. សូមពិចារណាលើសំណួរខាងក្រោម ហើយគូសសញ្ញាគ្រីស (✓) ក្នុងប្រអប់មួយដែលសមរម្យ៖

| | ខ្ញុំ | ព្រះយេស៊ូវ |
|---|---|---|
| តើនរណាជាអ្នកដែលដឹងយ៉ាងប្រាកដថាអ្វីជាការល្អបំផុតសម្រាប់ជីវិតខ្ញុំ? | ☐ | ☐ |
| តើនរណាជាអ្នកដែលអាចធ្វើការល្អបំផុតសម្រាប់ជីវិតខ្ញុំបាន? | ☐ | ☐ |
| តើនរណាជាអ្នកដែលប្រាថ្នារកតែសេចក្ដីពិតសម្រាប់ជីវិតខ្ញុំ? | ☐ | ☐ |

ទោះបីជាយើងដឹងថា ព្រះជាម្ចាស់ល្អយ៉ាងណាក៏ដោយ ចុះហេតុអ្វីបានជាយើងគិតថា វានៅតែពិបាកក្នុងការចុះចូលចំពោះការដែលព្រះជាម្ចាស់គ្រប់គ្រងលើជីវិតរបស់យើងយ៉ាងដូច្នេះ?

១២. តើព្រះជាម្ចាស់បានប្រទានអ្វី ដើម្បីជួយឲ្យយើងចេះទុកចិត្តព្រះគ្រីស្ទ និងស្តាប់បង្គាប់ទ្រង់ដែលជាព្រះអម្ចាស់របស់យើង?
(២ពេត្រុស ១:៣-៤)



## ផ្អាកបន្តិចដើម្បីអធិស្ឋាន

សូមផ្អាកបន្តិច ដើម្បីអធិស្ឋានចំពោះការដែលព្រះយេស៊ូវគង់នៅក្នុងចិត្តរបស់លោកអ្នក។ សូមទូលទ្រង់ពីអារម្មណ៍លោកអ្នកទាក់ទងនឹងការលះបង់ខ្លួនឯង ដើម្បីឈានចូលទៅក្នុងអំណាចរបស់ទ្រង់ និងទុកចិត្តលើភាពជាម្ចាស់របស់ទ្រង់ក្នុងគ្រប់ទាំងផ្នែកនៃជីវិតរបស់លោកអ្នក។ ចូរទទួលស្គាល់គ្រប់ទាំងសេចក្តីភ័យខ្លាចដែលលោកអ្នកមាន ហើយអនុញ្ញាតឲ្យទ្រង់ដឹងឮពីការប្តេជ្ញាចិត្តរបស់លោកអ្នកផងដែរ។

# ការទទួលស្គាល់ភាពជាព្រះអម្ចាស់របស់ទ្រង់ក្នុងការអនុវត្ត

បំណងល្អមិនប្រាកដថានឹងបានទទួលលទ្ធផលល្អនោះទេ។ ការចាប់ផ្តើមល្អមិនប្រាកដថាបានបញ្ចប់ដោយជោគជ័យនោះដែរ ហើយការសម្រេចចិត្តគឺគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ។ នៅពេលណាដែលលោកអ្នកសម្រេចចិត្តទទួលស្គាល់ភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទក្នុងជីវិត នោះលោកអ្នកនឹងអះអាងថា ទ្រង់គឺជាព្រះអម្ចាស់ ហើយព្រមចុះចូល និងស្តាប់បង្គាប់ទ្រង់គ្រប់ពេលវេលា នៅក្នុងជីវិតរបស់លោកអ្នក។ ចំណុចទាំងនេះគឺបង្ហាញឲ្យឃើញតាមរូបភាពដូចខាងក្រោម។



១៣. សូមចំណាយពេលបន្តិច ដើម្បីវាយតម្លៃលើការចុះចូលរបស់លោកអ្នក ចំពោះភាពជាព្រះអម្ចាស់របស់ព្រះយេស៊ូវគ្រីស្ទ ត្រង់ចំណុចទាំងប៉ុន្មានខាងក្រោមនេះ។ របៀបដ៏ល្អមួយ ដើម្បីកំណត់ថា តើព្រះគ្រីស្ទគ្រប់គ្រងលើជីវិតយើងឬក៏អត់នោះ គឺត្រូវសួរខ្លួនឯងថា «តើខ្ញុំមានឆន្ទៈក្នុងការធ្វើនូវរាល់កិច្ចការដែលព្រះគ្រីស្ទសព្វព្រះហឫទ័យនៅត្រង់ចំណុចនេះដែរឬទេ?» ឬក៏ «តើខ្ញុំអាចនឹងអរព្រះគុណព្រះជាម្ចាស់ចំពោះអ្វីដែលកើតឡើងត្រង់ចំណុចនេះដែរឬទេ?»

ក) តើមានចំណុចណាខ្លះនៅក្នុងរូបភាពកង់រទេះដែលលោកអ្នកមិនទាន់បានអនុញ្ញាតឲ្យព្រះគ្រីស្ទគ្រប់គ្រងនៅឡើយ?

ខ) តើមានចំណុចណាផ្សេងទៀតក្រៅពីក្នុងរូបភាពខាងលើដែលលោកអ្នកមិនបានអនុញ្ញាតឲ្យព្រះគ្រីស្ទគ្រប់គ្រងដែរឬទេ? សូមពន្យល់ពីចំណុចទាំងនោះ ហើយហេតុអ្វីបានជាលោកអ្នកស្ទាក់ស្ទើរក្នុងការទុកចិត្តលើអំណាចរបស់ព្រះយេស៊ូវនៅត្រង់ចំណុចនេះ។

គ) តើលោកអ្នកអាចធ្វើអ្វីខ្លះ ត្រង់ចំណុចនេះ ដើម្បីយាងព្រះវត្តមាននៃភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទមកក្នុងជីវិតបាន?

# ការពិនិត្យកសារធាតុពិត



ប្រសិនបើយើងមានលុយច្រើន ពេលវេលា ឬការអប់រំច្រើនហើយនោះ យើងមិនគួរនឹងអំពល់ពីអ្វីដែលយើងគួរធ្វើសម្រាប់ព្រះជាម្ចាស់ឡើយ។ ផ្ទុយទៅវិញ យើងត្រូវសម្រេចចិត្តនូវអ្វីដែលយើងនឹងត្រូវធ្វើជាមួយអ្វីៗដែលយើងមានឥឡូវនេះ។ ហើយអ្វីដែលជាបញ្ហាពិតប្រាកដនោះ គឺមិនមែនថាយើងជាអ្នកណា ឬជាអ្វីនោះទេ ប៉ុន្តែកត្តាដែលសំខាន់នោះគឺថា តើព្រះគ្រីស្ទគ្រប់គ្រងយើងឬក៏អត់?

១៤. នៅរាល់ពេលណាដែលលោកអ្នកចង់គ្រប់គ្រងលើជីវិតរបស់លោកអ្នក រំពេចនោះលោកអ្នកនឹងមិនសប្បាយចិត្តព្រមទាំងខ្វល់ខ្វាយទៀតផង។ តើសាវ័ក ពេត្រុស មានប្រសាសន៍ថា លោកអ្នកអាចធ្វើអ្វីបានខ្លះ? (១ពេត្រុស ៥:៦-៧)

១៥. តើមានអ្វីអាចនឹងកើតឡើង ប្រសិនបើលោកអ្នកមិនថ្វាយការខ្វល់ខ្វាយ និងសេចក្តីទុក្ខព្រួយដល់ព្រះគ្រីស្ទ? (ម៉ាកុស ៤:១៨-១៩)

តើលោកអ្នកគិតថា ការនេះកើតឡើងបានដោយរបៀបណា?



១៦. នៅក្នុងកណ្ឌគម្ពីរ លូកា ៩:២៣ តើចំណុចបីយ៉ាងដែលព្រះជាម្ចាស់បានត្រាស់ហៅឲ្យអ្នកដើរតាមព្រះគ្រីស្ទធ្វើនោះមានអ្វីខ្លះ? (សូមសរសេរចំណុចទាំងនោះតាមយោបល់របស់លោកអ្នកផ្ទាល់)។

១៧. យោងតាមកណ្ឌគម្ពីរ លូកា ៦:៤៦ តើអ្វីជាមធ្យោបាយដ៏ល្អក្នុងការវាយតម្លៃថា ព្រះយេស៊ូវពិតជាព្រះអម្ចាស់នៃជីវិតរបស់លោកអ្នកមែន?

១៨. សូមអានកណ្ឌគម្ពីរ លូកា ១៨:២៨-៣០។

ក) តើពួកសាវ័កបានធ្វើអ្វីខ្លះ?

ខ) ក្នុងនាមជាព្រះអម្ចាស់ តើព្រះយេស៊ូវបានសន្យាយ៉ាងដូចម្តេចចំពោះអស់អ្នកដែលដើរតាមទ្រង់?

គ) សូមពណ៌នាអំពីពេលវេលា ឬក៏ស្ថានភាពផ្ទាល់ណាមួយរបស់លោកអ្នក នៅពេលដែលលោកអ្នកបានធ្វើតាមគំរូរបស់ពួកសាវ័ក។ តើមានឥទ្ធិពលអ្វីមកលើរូបលោកអ្នក និងអ្នកដទៃ?

១៩. តើព្រះគ្រីស្ទអនុវត្តការការពារសេចក្តីស្រឡាញ់ និងភាពជាព្រះអម្ចាស់របស់ទ្រង់ចំពោះអ្នកដើរតាមទ្រង់យ៉ាងដូចម្តេច? (អេភេសូរ ៥:២៤-២៧)

២០. តើភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទមានអត្ថន័យយ៉ាងដូចម្តេចចំពោះលោកអ្នកផ្ទាល់?

# សំណើខគម្ពីរមួយសម្រាប់ការ សញ្ជឹងគិត និងការទន្ទេញចាំមាត់



កូល៉ុស ១:១៦

ដ្បិតគឺទ្រង់ហើយ ដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ នោះសុទ្ធតែកើតមកដោយសារទ្រង់ ហើយសំរាប់ទ្រង់ទាំងអស់ផង

កូល៉ុស ១:១៦

# សៀវភៅកំណត់ហេតុរបស់ខ្ញុំ

ដើម្បីទទួលស្គាល់ថា ផែនការរបស់ព្រះយេស៊ូវសម្រាប់ជីវិតរបស់លោកអ្នក ប្រសើរជាងផែនការដែលលោកអ្នកមានសម្រាប់ខ្លួនឯង គឺទាមទារឲ្យលោកអ្នក បន្ទាបខ្លួនយ៉ាងពិតប្រាកដ។ ដើម្បីឲ្យទ្រង់សោយរាជ្យលើជីវិតរបស់លោកអ្នក ហើយយាងព្រះវត្តមានទ្រង់មកគង់នៅក្នុងលោកអ្នកបាន គឺទាមទារឲ្យលោកអ្នក ទុកចិត្តលើទ្រង់ឲ្យអស់ពីចិត្ត។ សូមពិចារណាទៅលើសម្រង់សម្ដីខាងក្រោម នេះ។ បន្ទាប់សូមសរសេរកំណត់ហេតុស្ដីពីកម្រិតនៃបំណងចិត្តក្នុងការដើរ តាមទ្រង់ទុកជាព្រះអម្ចាស់របស់លោកអ្នក។

> *“តើលោកអ្នកបានថ្វាយខ្លួនដល់នរណា? ព្រះអម្ចាស់យេស៊ូវ។ តើលោកអ្នកបានដើរតាមផ្លូវរបស់នរណា? ព្រះអម្ចាស់។ តើលោកអ្នកបានឮសេចក្ដីពិតពីនរណា? ព្រះអម្ចាស់នេះហើយ។ តើលោកអ្នកបានទទួលជីវិតពីនរណា? ព្រះអម្ចាស់។ បើលោកអ្នកដើរតាមទ្រង់ដែលជាផ្លូវដ៏ពិត នោះលោកអ្នកនឹងឮព្រះសូរសៀងដែលជាសេចក្ដីពិត ហើយទ្រង់នឹងប្រទានជីវិតដល់លោកអ្នកព្រោះទ្រង់គឺជាប្រភពនៃជីវិត”។*

លោក ជីន ហ្គាយ៉ុន (Jean Guyon)

## ចំណុចគួរចងចាំ

- នៅក្នុងព្រះគម្ពីរបានប្រកាសថា ព្រះយេស៊ូវគឺជាព្រះអម្ចាស់។ ដោយព្រោះតែទ្រង់គឺជាព្រះ ហើយគ្រប់កិច្ចការដែលទ្រង់ធ្វើកន្លងមកនោះបានបញ្ជាក់ថា ព្រះអង្គស័ក្តិសមធ្វើជាព្រះអម្ចាស់។
- ពីព្រោះព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ ដូច្នេះការទទួលខុសត្រូវរបស់អ្នកជឿគឺត្រូវទទួលស្គាល់ពីអំណាចរបស់ទ្រង់ជារៀងរាល់ថ្ងៃនៅគ្រប់ផ្នែកនៃជីវិតរបស់ខ្លួន។
- មានផ្នែកខ្លះៗនៅក្នុងជីវិតរបស់អ្នកជឿគ្រប់រូបនៅមិនទាន់ចុះចូលចំពោះព្រះគ្រីស្ទនៅឡើយទេ។ អ្នកដើរតាមព្រះយេស៊ូវគួរតែចុះចូលគ្រប់ផ្នែកទាំងនោះទៅចំពោះព្រះគ្រីស្ទ ហើយបន្តទទួលស្គាល់ថា ការគ្រប់គ្រងរបស់ព្រះគ្រីស្ទក្នុងជីវិតរបស់ពួកគេ គឺប្រយោជន៍សម្រាប់សេចក្តីល្អ និងសេចក្តីអំណររបស់ខ្លួនពួកគេផ្ទាល់តែប៉ុណ្ណោះ។

# ការចូលឲ្យបានស៊ីជម្រៅ

សូមសញ្ជឹងគិតទៅលើខគម្ពីរនីមួយៗនៅក្នុងកណ្ឌគម្ពីរ កូល៉ុស ១:១៣-២២។ សូមសង្ខេបខគម្ពីរនីមួយៗដែលស្ដីពីការពិតអំពីព្រះអម្ចាស់យេស៊ូវ ឬក៏ពីការពិតអំពីលោកអ្នកដែលជាអ្នកដើរតាមទ្រង់តាមការយល់ឃើញរបស់លោកអ្នកដាក់ក្នុងតារាងខាងក្រោមនេះ៖

| ខគម្ពីរ | ការពិតអំពីព្រះអម្ចាស់យេស៊ូវ | ការពិតអំពីលោកអ្នក |
|---|---|---|
| ១៣ | | |
| ១៤ | | |
| ១៥ | | |
| ១៦ | | |
| ១៧ | | |
| ១៨ | | |
| ១៩ | | |
| ២០ | | |
| ២១ | | |
| ២២ | | |

តើសេចក្ដីពិត និងការធានាដែលមកពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ទាំងអស់នេះ មានឥទ្ធិពលលើបំណងចិត្តរបស់លោកអ្នកក្នុងការចុះចូលដោយអំណរទៅនឹងភាពជាព្រះអម្ចាស់របស់ទ្រង់នៅក្នុងជីវិតរបស់លោកអ្នកយ៉ាងដូចម្ដេច?

ជំពូកទី

# ៣

# ជំនឿនិងសេចក្ដីសន្យារបស់ព្រះជាម្ចាស់

មានម្ដងនោះ មានមនុស្សមួយក្រុមបានសួរព្រះយេស៊ូវពីរបៀបដែលពួកគេអាចធ្វើការរបស់ព្រះជាម្ចាស់។ ព្រះយេស៊ូវមានបន្ទូលឆ្លើយតបថា “ឯការរបស់ព្រះ គឺឲ្យអ្នករាល់គ្នាបានជឿដល់អ្នកដែលព្រះបានចាត់ឲ្យមក” (យ៉ូហាន ៦:២៩)។ ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងជឿ ហើយមានជំនឿ “ដ្បិតបើឥតមានសេចក្ដីជំនឿទេ នោះមិនអាចនឹងគាប់ព្រះហឫទ័យព្រះបានឡើយ” (ហេព្រើរ ១១:៦)។

ប៉ុន្តែជារឿយៗជំនឿរបស់យើងគឺមិនមានអ្វីដែលលើសជាងការគិតដែលពោរពេញដោយក្ដីប៉ងប្រាថ្នានោះដោយពោលថា “ខ្ញុំសង្ឃឹមថា គ្រប់ការទាំងអស់នឹងដំណើរការទៅបានយ៉ាងល្អ។ ដោយព្រោះខ្ញុំមានជំនឿថាវានឹងសម្រេចបាន”។ តែទស្សនវិស័យនៅក្នុងព្រះគម្ពីរស្ដីពីជំនឿ គឺខ្ពស់ហួសពីទស្សនៈនៃជំនឿដ៏រាក់កំភែលខាងលើនេះទៅទៀត។ ជំនឿក្នុងព្រះគម្ពីរលើកឡើងថា “ព្រះអម្ចាស់អើយ ទូលបង្គំទុកចិត្តទ្រង់ជានិច្ច!”

# ការដើរដោយជំនឿ



១. តើជំនឿរបស់យើងទាក់ទងជាមួយការទទួលបានសេចក្តីសង្គ្រោះយ៉ាងដូចម្តេច? (អេភេសូរ ២:៨-៩)

តើលោកអ្នកគួររស់នៅយ៉ាងដូចម្តេច បន្ទាប់ពីលោកអ្នកបានទទួលព្រះគ្រីស្ទដោយជំនឿរួចមក? (កូល៉ុស ២:៦)

២. តើលោកអ្នកអាចឲ្យនិយមន័យលើពាក្យថា “ជំនឿ” ចេញពីខគម្ពីរខាងក្រោមនេះបានយ៉ាងដូចម្តេច?

កិច្ចការ ២៧:២៥

រ៉ូម ៤:២០-២១

ហេព្រើរ ១១:១

> *ជំនឿគឺជាការធានាថាអ្វីដែលព្រះជាម្ចាស់មានបន្ទូលពិតទាំងអស់ ទាំងធានាថាព្រះជាម្ចាស់នឹងធ្វើតាមគ្រប់ការដែលទ្រង់មានបន្ទូលក្នុងព្រះគម្ពីររបស់ទ្រង់។ ....ជំនឿមិនមែនគ្រាន់តែជាចំណាប់អារម្មណ៍ ការប៉ាន់ប្រមាណ ឬក៏ជាលក្ខណៈខាងក្រៅនោះឡើយ។*
>
> លោក ជច មូលើរ (George Muller)
> ដកស្រង់ចេញពីសៀវភៅ *Man of Faith and Miracles*

៣. តើជំនឿអាចនាំឲ្យកើតមានការអ្វីខ្លះ? សូមផ្គូផ្គងប្រយោគខាងក្រោមនេះ៖

| | |
|---|---|
| ____សង្ឃឹម អំណរ សុខសាន្ត | ក) ម៉ាថាយ ២១:២២ |
| ____ការឆ្លើយតបចំពោះការអធិស្ឋាន | ខ) យ៉ាកុប ២:២៣ |
| ____មានអំណាចលើសាតាំង | គ) អេភេសូរ ៣:១២ |
| ____ការចូលទៅចំពោះព្រះជាម្ចាស់ | ឃ) អេភេសូរ ៦:១៦ |
| ____ស្គាល់ព្រះជាម្ចាស់យ៉ាងស្និទ្ធស្នាល | ង) រ៉ូម ១៥:១៣ |

ជំនឿដ៏ពិតប្រាកដមិនមែនគ្រាន់តែយល់ដឹងពីសេចក្ដីពិតអំពីព្រះជាម្ចាស់ប៉ុណ្ណោះនោះទេ ប៉ុន្តែវាតែងតែនាំយើងទៅរកភាពស្និទ្ធស្នាលជាមួយទ្រង់យ៉ាងអស់ពីចិត្តផងដែរ។

៤. សូមសរសេរចុះនូវគោលការណ៍មួយចំនួនចេញពីកណ្ឌគម្ពីរ ២កូរិនថូស ៥:៧ ឡើងវិញតាមគំនិតលោកអ្នកផ្ទាល់។ បន្ទាប់មកសូមឲ្យឧទាហរណ៍ពីរបៀបដែលលោកអ្នកអាចអនុវត្តនូវសេចក្ដីពិតនេះក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់លោកអ្នក។

៥. តើអំពើបាបប្រភេទណាខ្លះដែលអាចធ្វើឲ្យលោកអ្នកមើលមិនឃើញពីកិច្ចការរបស់ព្រះជាម្ចាស់? (ម៉ាថាយ ១៣:៥៨)

> “ *អ្វីដែលផ្ទុយនឹងជំនឿមិនមែនជាមន្ទិលសង្ស័យនោះទេ តែវាគឺជាការមិនជឿទៅវិញទេ។ មន្ទិលសង្ស័យត្រូវការត្រឹមតែហេតុការណ៍ជាក់ស្ដែងថែមទៀតប៉ុណ្ណោះ។ ឯការមិនជឿគឺសំដៅលើការមិនស្ដាប់បង្គាប់ ហើយបដិសេធក្នុងការប្រព្រឹត្តតាមអ្វីដែលព្រះជាម្ចាស់មានបន្ទូល។*
>
> កែសម្រួលពីលោកគ្រូ ឆាលស៍ ជី. ហ្វីននី (Charles G. Finney)
> ដកស្រង់ចេញពីសៀវភៅ *Systematic Theology*

៦. សូមអានរឿងពីការតយុទ្ធដោយមន្ទិលសង្ស័យរបស់សាវ័ក ថូម៉ាស នៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ២០:២៤-២៩។ តើព្រះយេស៊ូវបានឆ្លើយតបទៅនឹងមន្ទិលសង្ស័យរបស់គាត់យ៉ាងដូចម្ដេច?

តើលោកអ្នករំពឹងចង់ឲ្យព្រះយេស៊ូវឆ្លើយតបនឹងលោកអ្នកយ៉ាងដូចម្ដេច នៅពេលដែលលោកអ្នកមានមន្ទិលសង្ស័យ?



“ *ជំនឿនៅក្នុងព្រះជាម្ចាស់គឺជាទំនាក់ទំនងមួយដែលពាក់ព័ន្ធជាមួយនឹង គ្រប់ទាំងផ្នែកនៃជីវិតលោកអ្នក និង គ្រប់អ្វីៗដែលនៅជុំវិញលោកអ្នក។ ជំនឿគឺជាការជួបដោយផ្ទាល់ ជាទំនាក់ទំនងនៃសេចក្ដីពិតជាមួយនឹងព្រះជាម្ចាស់។*

លោក លីអណាត ស្វីត (Leonard Sweet)
ដកស្រង់ចេញពីសៀវភៅ *Out of the Question...Into the Mystery: Getting Lost in the GodLife Relationship*

៧. តើមានមនុស្ស និងរបស់មិនគួរគប្បីណាខ្លះ ដែលមនុស្សយកមកគោរព ប្រតិបត្តិក្នុងជំនឿរបស់ពួកគេ?

ទំនុកដំកើង ៣៣:១៦-១៧

ទំនុកដំកើង ១៤៦:៣

សុភាសិត ៣:៥

សុភាសិត ២៨:២៦

យេរេមា ៩:២៣-២៤

សូមគូសសញ្ញាគ្រីស (✓) លើមនុស្សឬ អ្វីៗផ្សេងទៀត ដែលលោកអ្នកយល់ឃើញថា ភាគច្រើនលោកអ្នកពឹងផ្អែកលើ។ តើអ្វីទៅដែលលោកអ្នកគិតថាជាលទ្ធផលដែលនឹងត្រូវកើតឡើងដោយខានមិនបានចេញពីការដាក់ជំនឿទៅលើមនុស្ស និងវត្ថុទាំងអស់នោះ?

៨. តើអ្នកណាជាចំណុចធំបំផុតនៃជំនឿរបស់លោកអ្នក? (ម៉ាកុស ១១:២២)

៩. ទំនុកចិត្ត និងជំនឿរបស់លោកអ្នកក្នុងព្រះជាម្ចាស់ គឺបានសាងឡើងតាមរយៈការយល់ដឹងរបស់លោកអ្នកដោយការទទួលស្គាល់ពីភាពជាព្រះរបស់ព្រះជាម្ចាស់ និងលក្ខណៈដ៏ពិតរបស់ទ្រង់។ តើមានខគម្ពីរសំខាន់ៗណាខ្លះដែលបង្ហាញដល់លោកអ្នកអំពីនិស្ស័យ និងពីអត្តចរិតរបស់ព្រះជាម្ចាស់?

| **ខគម្ពីរ** | **តើខគម្ពីរនេះបង្ហាញខ្ញុំឲ្យដឹងអ្វីខ្លះអំពីព្រះជាម្ចាស់?** |
|---|---|
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |

## គំរូនៃជំនឿ



១០. កណ្ឌគម្ពីរ ហេព្រើរ ១១ គឺជាជំពូកគន្លឹះមួយស្តីពីជំនឿ។ សូមអានជំពូកនេះទាំងមូល ហើយកត់ចំណាំនូវរឿងមួយចំនួនដែលសម្រេចបានដោយសារជំនឿ។

ក) តើលោកអ្នកគិតថា រឿងមួយណានៅក្នុងកណ្ឌគម្ពីរ ហេព្រើរ ១១ ដែលសម្រេចបានដោយសារជំនឿ ហើយមានសារៈសំខាន់ជាងគេបំផុត? ហេតុអ្វី?

ខ) តើលោកអ្នកគិតថា ព្រះជាម្ចាស់បានបញ្ជ្រាបជំនឿរបស់មនុស្សដែលមានចែងនៅក្នុងកណ្ឌគម្ពីរ ហេព្រើរ ១១ ឲ្យបានកាន់តែជ្រាលជ្រៅឡើងដោយរបៀបណា? (ចំណាំ ជាពិសេសនៅក្នុង ៦៩, ១៧, ២៥, ៣៤, ៣៧-៣៨)។

គ) មានមនុស្សជាច្រើននៅក្នុងកណ្ឌគម្ពីរ ហេព្រើរ ១១ បានរង់ចាំអស់ជាច្រើនឆ្នាំ ឬក៏ពេញមួយជីវិតរបស់ពួកគេមុននឹងពួកគេបានឃើញការដែលព្រះជាម្ចាស់បំពេញសេចក្តីសន្យារបស់ទ្រង់។ តើនៅពេលព្រះជាម្ចាស់មានបន្ទូលមកលោកអ្នកឲ្យរង់ចាំ នោះនឹងមានអ្វីកើតឡើងចំពោះជំនឿរបស់លោកអ្នក?

> *ព្រះជាម្ចាស់មានព្រះទ័យរីករាយក្នុងការបង្កើនជំនឿកូនៗរបស់ទ្រង់...ខ្ញុំហ៊ាននិយាយហើយនិយាយទៀតដោយមិនសូញសាញថា សេចក្តីល្បួង ឧបសគ្គ ទុក្ខលំបាក និងការបោកបញ្ឆោតទាំងពួងនោះ ពេលខ្លះគឺជាអាហារដ៏ល្អនៃជំនឿ។*
>
> លោក ម៉ាលស៍ ជេ. ស្តែនហ្វដ (Miles J. Stanford)
> ដកស្រង់ចេញពីសៀវភៅ *Principles of Spiritual Growth*

## សេចក្តីសន្យារបស់ព្រះជាម្ចាស់

១១. សូមគិតពីស្ថានភាពដ៏ជាក់លាក់មួយ នៅពេលដែលមាននរណាម្នាក់សន្យាអ្វីមួយជាមួយលោកអ្នក។

ក) តើលោកអ្នកអាចវាយតម្លៃថា មនុស្សម្នាក់អាចរក្សាសេចក្តីសន្យាបាន ឬក៏អត់ បានដោយរបៀបណា?

ខ) តើគាត់បានរក្សាសេចក្តីសន្យាឬទេ?

គ) តើការនេះមានឥទ្ធិពលទៅលើអាកប្បកិរិយារបស់លោកអ្នកចំពោះសេចក្តីសន្យាដែលគាត់នឹងសន្យានៅថ្ងៃអនាគតទៀតយ៉ាងដូចម្តេច?

១២. ព្រះជាម្ចាស់ក៏បានសន្យាយ៉ាងពិតប្រាកដចំពោះលោកអ្នកផងដែរ។ តើបទគម្ពីរមានចែងយ៉ាងដូចម្តេច អំពីព្រះបន្ទូលរបស់ទ្រង់?

១ពង្សាវតារក្សត្រ ៨:៥៦

ទំនុកដំកើង ៨៩:៣៤

អេសាយ ៥៥:១១

២ពេត្រុស ១:៤

១៣. តាមការយល់ឃើញរបស់លោកអ្នក សូមគិតទៅមើលថា ហេតុអ្វីបានជាព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់គួរឲ្យទុកចិត្តបាន?

## សេចក្តីសន្យាដែលត្រូវទាមទារ

១៤. សូមបំពេញតារាងខាងក្រោម៖

| ខគម្ពីរ | សេចក្តីសន្យា | លក្ខខណ្ឌ |
|---|---|---|
| យ៉ូហាន ១៥:៧ | | |
| បរិទេវ ៣:២២-២៦ | | |
| រ៉ូម ៨:២៨ | | |

១៥. តាមការយល់ឃើញរបស់លោកអ្នក សូមគិតទៅមើលថា ហេតុអ្វីបានជាព្រះជាម្ចាស់ដាក់លក្ខខណ្ឌលើសេចក្ដីសន្យាខ្លះៗ?

១៦. តើព្រះជាម្ចាស់មានអាកប្បកិរិយាយ៉ាងដូចម្ដេចក្នុងការបំពេញសេចក្ដីសន្យារបស់ទ្រង់ចំពោះលោកអ្នក? (២កូរិនថូស ១:២០)



១៧. សូមអានកណ្ឌគម្ពីរ ហេព្រើរ ៦:១២, ១៦-១៩។

ក) តើលោកអ្នកគួរប្រកាន់អាកប្បកិរិយាបែបណាក្នុងការទាមទារយកសេចក្តីសន្យារបស់ព្រះជាម្ចាស់? (ខ១២)

ខ) ហេតុអ្វីបានជាមនុស្សសន្យា ហើយស្បថចំពោះគ្នាទៅវិញទៅមក? (ខ១៦)

គ) ហេតុអ្វីបានជាព្រះជាម្ចាស់សន្យាចំពោះកូនៗរបស់ទ្រង់? (ខ១៧-១៩)

ការកត់ចំណាំពីសេចក្តីសន្យារបស់ព្រះជាម្ចាស់មិនត្រឹមតែមានសារប្រយោជន៍នោះទេ តែវាថែមទាំងជួយលើកទឹកចិត្តយើងផងដែរ។ លោកអ្នកអាចនឹងមានចិត្តចង់រក្សាទុកនូវតារាងនៃសេចក្តីសន្យា និងលក្ខខណ្ឌនៃសេចក្តីសន្យា ព្រមទាំងលទ្ធផលនៃសេចក្តីសន្យាទាំងនោះផងដែរ។ សេចក្តីសន្យារបស់ព្រះជាម្ចាស់មានលក្ខណៈប្រទាក់ក្រឡាគ្នាជា «ច្រវាក់» ដូចជាឧទាហរណ៍ខាងក្រោម៖






១៨. សូមស្វែងយល់ពីរបៀបដែលស្តេច យ៉ូសាផាត ប្រើសេចក្តីសន្យារបស់ព្រះជាម្ចាស់។ សូមអានកណ្ឌគម្ពីរ ២របាក្សត្រ ២០:១-៣០។



ក) តើស្តេច យ៉ូសាផាត បានធ្វើអ្វីមុនគេបង្អស់? (ខ៣, ៦-១២)

ខ) តើព្រះជាម្ចាស់បានឆ្លើយតបទៅស្តេច យ៉ូសាផាត យ៉ាងដូចម្តេច? (ខ១៥)

គ) តើនេះគឺជាសេចក្តីសន្យាឬ?

ឃ) តើការឆ្លើយតបបន្ទាប់ទៀតរបស់ស្តេច យ៉ូសាផាត គឺជាអ្វី? (ខ១៨)

ង) តើមានភស្តុតាងអ្វីដែលធ្វើឲ្យស្តេច យ៉ូសាផាត ជឿលើសេចក្តីសន្យារបស់ព្រះជាម្ចាស់នៅពេលនោះ?

ច) តើស្ដេច យ៉ូសាផាត បានលើកទឹកចិត្តដល់អ្នកដទៃទៀតដោយរបៀបណា? (ខ២០)

ឆ) តើលទ្ធផលនៃការនោះគឺជាអ្វី? (ខ២២, ២៧)

១៩. តើសេចក្ដីសន្យាមួយដែលលោកអ្នកបានរកឃើញនៅក្នុងការអានព្រះគម្ពីរជាប្រចាំនោះគឺអ្វី?

ជាងនេះទៅទៀត តើសេចក្ដីសន្យានេះបានជួយលោកអ្នកដោយរបៀបណា?

# សំណើខគម្ពីរមួយសម្រាប់ការ សញ្ជឹងគិត និងការទន្ទេញចាំមាត់



ហេព្រើរ ១១:៦

តែបើឥតមានសេចក្ដីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះ បានឡើយ ដ្បិតអ្នកណាដែលចូលទៅឯព្រះ នោះត្រូវតែជឿថា មានព្រះមែន ហើយថា ទ្រង់ប្រទានរង្វាន់ ដល់អស់អ្នកដែលស្វែងរកទ្រង់

ហេព្រើរ ១១:៦

# សៀវភៅកំណត់ហេតុរបស់ខ្ញុំ

តើលោកអ្នកបានឃើញថា ព្រះជាម្ចាស់បានបំពេញសេចក្ដីសន្យារបស់ទ្រង់ ចំពោះលោកអ្នកយ៉ាងដូចម្ដេចដែរ?

តើលោកអ្នកបានសន្យាអ្វីជាមួយនឹងព្រះជាម្ចាស់?

តើលោកអ្នកជាមនុស្សដែលទ្រង់ទុកចិត្តបានដែរឬទេ?

# ចំណុចគួរចងចាំ

- ជំនឿគឺសង្កត់ធ្ងន់ទៅលើភាពជាក់ស្តែងដែលថា ព្រះជាម្ចាស់គឺជាព្រះដែលគួរឲ្យទុកចិត្តបានក្នុងការរក្សាសេចក្តីសន្យា ហើយបំពេញតាមគ្រប់ទាំងសេចក្តីសន្យារបស់ទ្រង់។

- ប្រហែលជាមានមនុស្សមួយចំនួនបានផ្ញើជីវិតរបស់គេទៅលើរឿងផ្សេងៗដែលនឹងត្រូវវិនាសនៅថ្ងៃណាមួយ។ មានតែព្រះជាម្ចាស់មួយប៉ុណ្ណោះដែលស័ក្តិសមឲ្យយើងជឿ។

- ព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនដែលប្រែប្រួលឡើយ។ ព្រះជាម្ចាស់តែងតែធ្វើនូវអ្វីដែលទ្រង់មានបន្ទូល ទ្រង់នឹងធ្វើឲ្យសម្រេចពីព្រោះទ្រង់ស្មោះត្រង់នឹងព្រះបន្ទូលរបស់ទ្រង់។

- អ្នកជឿគ្រប់រូបគួរតែទាមទារយកសេចក្តីសន្យារបស់ព្រះជាម្ចាស់ ព្រោះទ្រង់មានបំណងព្រះហឫទ័យឆ្លើយតបទៅនឹងជំនឿរបស់យើង។

# ការចូលឲ្យបានស៊ីជម្រៅ

នៅក្នុងសម័យកាលលោក នេហេមា ព្រះជាម្ចាស់បានធ្វើការដ៏អស្ចារ្យមួយ ដើម្បីស្តារប្រជារាស្ត្រអ៊ីស្រាអែលឡើងវិញ។ ដោយសារការស្តារឡើងវិញនេះ ពួកសង្ឃលេវី និងអ្នកដឹកនាំផ្សេងទៀតបានសម្ដែងពីជំនឿដ៏ធំធេងរបស់ពួកគេ ដូចដែលមានចែងនៅក្នុងកណ្ឌគម្ពីរ នេហេមា ៩។

ពួកសង្ឃលេវីបានបង្ហាញពីលក្ខណៈដ៏អស្ចារ្យមួយចំនួនអំពីព្រះជាម្ចាស់ ដោយជំនឿ។ នៅក្នុងម្តេខដំបូង បណ្ដាជនបាននាំគ្នាសរសើរតម្កើងព្រះជាម្ចាស់ ដោយសារទ្រង់៖

- មានព្រះនាមដ៏រុងរឿង (ខ៥)
- ជាព្រះតែ១ និងឯកអង្គ (ខ៦)
- ជាព្រះអាទិករដែលបង្កើតអ្វីៗទាំងអស់ចេញពីភាពទទេ (ខ៦)
- ប្រទានឲ្យមានជីវិត (ខ៦)
- ស័ក្តិសមនឹងទទួលការសរសើរ (ខ៦)
- មានអធិបតេយ្យភាព គ្រប់គ្រងលើអ្វីៗទាំងអស់ (ខ៧)
- ជាអ្នករំដោះ (ខ៧)
- ជាព្រះដែលដាក់ឈ្មោះឲ្យគេ (ខ៧)
- ជាព្រះដែលធ្វើតាមសេចក្តីសន្យា (ខ៨)
- មានភាពសុចរិត (ខ៨)
- យល់ពីការឈឺចាប់ (ខ៩)
- ជាព្រះដែលធ្វើការអស្ចារ្យ អាចផ្លាស់ប្តូរអ្វីគ្រប់បែបយ៉ាង (ខ១០)
- ជាព្រះដ៏ជាជំនួយ និងជាអ្នកដឹកនាំ (ខ១២)
- ជាព្រះដែលប្រទានឲ្យមានច្បាប់យុត្តិធម៌ដ៏ត្រឹមត្រូវ (១៣)
- ជាព្រះដែលផ្គត់ផ្គង់ (ខ១៥)
- ជាព្រះដែលពោរពេញដោយព្រះគុណ មេត្តាករុណា និងការអត់ទោស (ខ១៧)

- ជាអ្នកដឹកនាំដ៏ស្មោះត្រង់ (ខ១៩)
- ជាព្រះដែលមិនបោះបង់ចោលយើង (ខ១៩)
- ជាគ្រូបង្រៀន (ខ២០)

សូមសញ្ជឹងគិតលើកណ្ឌគម្ពីរ នេហេមា ៩:២១-២៧។ បន្ទាប់មក សរសេរបន្ថែមនូវពាក្យ ឬក៏ឃ្លាផ្សេងៗដែលពណ៌នាអំពីព្រះជាម្ចាស់ដូចចំណុចដែលបានរៀបរាប់នៅទំព័រមុន។

## ផ្អាកបន្តិចដើម្បីអធិស្ឋាន



សូមប្រើចំណុចដែលបានដកស្រង់ចេញពីកណ្ឌគម្ពីរនេហេមា ៩:១-២០ខាងលើនេះ ដើម្បីនាំលោកអ្នកឲ្យចូលទៅក្នុងពេលវេលាមួយនៃការថ្វាយបង្គំ ព្រមទាំងសរសើរតម្កើងព្រះជាម្ចាស់។ ហើយអរព្រះគុណទ្រង់ចំពោះគ្រប់ទាំងហេតុផលដែលនាំលោកអ្នកឲ្យទុកចិត្តទ្រង់យ៉ាងពេញទំហឹង។

ជំពូកទី

# ៤

# ការស្គាល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់

ពេលខ្លះលោកអ្នកហាក់ដូចជាមានអារម្មណ៍ថា ព្រះជាម្ចាស់បានបង្កប់នូវបំណងព្រះហឫទ័យរបស់ទ្រង់ដូចជាកំណប់ដែលគេកប់ទុកយ៉ាងដូច្នោះដែរ។ ប៉ុន្តែតើវាជាការពិតដែរឬទេ? តើព្រះជាម្ចាស់ពិតជាបង្កប់នូវបំណងព្រះហឫទ័យរបស់ទ្រង់ទុកជាការសម្ងាត់ឬ? ឬក៏ទ្រង់អនុញ្ញាតឲ្យលោកអ្នកដើរតាមទ្រង់ ហើយដឹកនាំលោកអ្នកមួយជំហានម្តងៗ?

កណ្ឌគម្ពីរ សុភាសិត ៣:៥-៦ លើកទឹកចិត្តយើងដូចតទៅៈ

> ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ នោះទ្រង់នឹងតម្រង់អស់ទាំងផ្លូវច្រករបស់ឯង

គន្លឹះដែលនាំឲ្យលោកអ្នកស្គាល់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺការយល់ពីព្រះតម្រិះរបស់ទ្រង់ដែលមានចំពោះលោកអ្នកផ្ទាល់ និងការអភិវឌ្ឍនូវទំនាក់ទំនងដ៏ល្អមួយជាមួយនឹងទ្រង់។

“ *បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់មិនមែនដូចជាកញ្ចប់វេទមន្តមួយដែលធ្លាក់មកពីស្ថានសួគ៌តាមខ្សែកាបនោះឡើយ។ ព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺដូចជាក្រាំងរមូរដែលទ្រង់លាបង្ហាញរាល់ថ្ងៃ។ ...យើងត្រូវយល់ដឹងពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ព្រមទាំងធ្វើតាមជារៀងរាល់ថ្ងៃអស់មួយជីវិត។ បំណងព្រះហឫទ័យរបស់ទ្រង់មិនមែនជាវត្ថុមួយដែលយើងចាប់ម្តងបានទាំងអស់ដូចកញ្ចប់អ្វីមួយនោះទេ។ ព្រះជាម្ចាស់ត្រាស់ហៅយើងមិនមែនឲ្យយើងដើរតាមគម្រោង ឬក៏ប្លង់ ឬក៏ទៅកន្លែងណាមួយ ឬក៏ទៅធ្វើការងារណាមួយនោះទេ ប៉ុន្តែគឺឲ្យដើរតាមព្រះអម្ចាស់យេស៊ូវគ្រីស្ទជាជាងការទាំងនោះវិញ។*

លោក ប៉ុល លីថល (Paul Little)
ដកស្រង់ចេញពីសៀវភៅ *Affirming the Will of God*



## ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលទ្រង់បានបើកសម្តែង

១. តើលោកអ្នកគួរតែមានបំណងប្រាថ្នាបែបណា ក្នុងនាមជាអ្នកដើរតាមព្រះគ្រីស្ទ? (អេភេសូរ ៥:១៧)

២. តើព្រះជាម្ចាស់បានសន្យាអ្វីចំពោះលោកអ្នក ទាក់ទងទៅនឹងព្រះហឫទ័យរបស់ទ្រង់សម្រាប់ជីវិតលោកអ្នក ហើយតើការនេះបង្ហាញអំពីព្រះហឫទ័យរបស់ទ្រង់ចំពោះលោកអ្នកយ៉ាងដូចម្តេច?
(ទំនុកដំកើង ៣២:៨)

៣. យោងតាមខគម្ពីរខាងក្រោមនេះ តើព្រះជាម្ចាស់បានបើកបង្ហាញអ្វីខ្លះអំពីបំណងព្រះហឫទ័យរបស់ទ្រង់ចំពោះលោកអ្នក?

១ថែស្សាឡូនីច ៤:៣

១ថែស្សាឡូនីច ៥:១៨

៤. តើអ្នកនិពន្ធកណ្ឌគម្ពីរ ទំនុកដំកើង ៤០:៨ មានឥរិយាបថបែបណាចំពោះព្រះហឫទ័យរបស់ព្រះជាម្ចាស់?

តើសកម្មភាពបែបណាដែលជួយបង្កើតឲ្យមានឥរិយាបថនេះឡើង?
(សូមមើលកណ្ឌគម្ពីរ ទំនុកដំកើង ៤០:៨, ១០)

៥. តើនរណាជាប្រភពនៃកម្លាំងរបស់លោកអ្នក ដើម្បីឲ្យលោកអ្នកធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់?
យ៉ូហាន ១៥:៥

ភីលីព ២:១៣

ជារឿយៗ យើងតែងតែជួបប្រទះនឹងការសម្រេចចិត្ត ចំពោះបញ្ហាដែលបទគម្ពីរមិនបានផ្តល់នូវការណែនាំជាក់លាក់ណាមួយនោះទេ។ នៅក្នុងករណីដូចនេះ អ្នកដើរតាមព្រះយេស៊ូវគួរតែអនុវត្តទៅលើគោលការណ៍នៃការសម្រេចចិត្តដែលមាននៅក្នុងព្រះបន្ទូល។

# គោលការណ៍នៃការសម្រេចចិត្ត



មនុស្សបានសាកល្បងប្រើប្រាស់វិធីសាស្ត្រផ្សេងៗជាច្រើន ដើម្បីស្គាល់ពីអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យគេធ្វើ។

- រោមចៀម (ទូលសូមព្រះជាម្ចាស់ប្រទាននូវទីសម្គាល់ដ៏អស្ចារ្យ)
- ការតម (ការមិនទទួលទានអាហារ ដើម្បីស្វែងរកព្រះជាម្ចាស់)
- ការបោះកាក់ (អាស្រ័យលើលទ្ធផលជាក់ស្ដែងនៃការបោះកាក់)
- អារម្មណ៍ (ស្ដាប់តាមតែអារម្មណ៍គេប៉ុណ្ណោះ)
- ការប្រវេប្រវា (ស្ទូចគ្រប់កន្លែង ដើម្បីឲ្យបានចម្លើយ)
- បណ្ដែតបណ្ដោយ (បណ្ដោយតាមហេតុការណ៍)
- ចាក់គម្ពីរ (អានខគម្ពីរដោយព្រាវៗ)
- សម្រេចជំនួស (សុំអ្នកផ្សេងឲ្យសម្រេចចិត្តជំនួសខ្លួន)
- សុបិន្ត (សុំឲ្យមានការជាក់ស្ដែងមួយ ឬសំឡេងមួយ)
- អង្គុយចុះ (អែអង់ក្នុងការសម្រេចចិត្ត)
- កម្ជិល (ជ្រើសរើសផ្លូវស្រួលជាងគេ)
- ការគិត (ប្រើតក្កវិជ្ជាជាជាងប្រើអារម្មណ៍)*

៦. ប្រសិនបើមាន តើចំណុចណាខ្លះដែលលោកអ្នកធ្លាប់សាកល្បង? តើមានលទ្ធផលអ្វីបានកើតឡើង?

---

* មកពី *How Can I Know What God Wants Me to Do?* Radio Bible Class Publication (Grand Rapids, MI, ឆ្នាំ១៩៨៧), ទំព័រ៣។

## គោលបំណងតាមបទគម្ពីរ

ព្រះជាម្ចាស់បានប្រទានបញ្ញត្តិជាពិសេសដែលអាចជួយឲ្យលោកអ្នកសម្រេចចិត្តតាមព្រះហឫទ័យទ្រង់។ ប្រសិនបើការសម្រេចចិត្តមួយនោះមិនស្របតាមព្រះគម្ពីរទេ នោះលោកអ្នកនឹងដឹងថា វាមិនមែនជាព្រះហឫទ័យរបស់ព្រះជាម្ចាស់ចំពោះលោកអ្នកទេ។

៧. ចូរប្រើខគម្ពីរខាងក្រោម ដោយបញ្ជាក់តាមគំនិតផ្ទាល់ខ្លួនរបស់លោកអ្នកអំពីគោលបំណងខ្លះៗដែលព្រះជាម្ចាស់មានចំពោះលោកអ្នក។

ម៉ាថាយ ៦:៣៣

ម៉ាថាយ ២២:៣៧-៣៩

២កូរិនថូស ៥:២០

១ពេត្រុស ១:១៥

២ពេត្រុស ៣:១៨

សូមសួរខ្លួនឯងនូវសំណួរខាងក្រោមនេះ ដោយយោងតាមខគម្ពីរនៅទំព័រមុន និងខគម្ពីរស្រដៀងគ្នាផ្សេងទៀត ដើម្បីប្តេជ្ញានូវអ្វីដែលលោកអ្នកនឹងធ្វើ៖



- តើខ្ញុំកំពុងតែដាក់បំណងព្រះហឫទ័យព្រះជាម្ចាស់សំខាន់ជាងបំណងរបស់ខ្ញុំដែរឬទេ?
- តើការនេះនឹងជួយខ្ញុំឲ្យស្រឡាញ់ព្រះជាម្ចាស់ និងអ្នកដទៃកាន់តែខ្លាំងថែមទៀតដែរឬទេ?
- តើការនេះនឹងជួយឲ្យខ្ញុំបំពេញមហាបេសកកម្មបានដែរឬទេ?
- តើការនេះនឹងជួយឲ្យខ្ញុំរស់នៅកាន់តែបរិសុទ្ធ ហើយមានចិត្តមេត្តាដែរឬទេ?
- តើការនេះនឹងចម្រើនភាពស្និទ្ធស្នាល និងការថ្វាយបង្គំរបស់ខ្ញុំចំពោះព្រះជាម្ចាស់ដែរឬទេ?

ការឆ្លើយតបនឹងសំណួរទាំងនេះដោយចេញពីចិត្តនឹងជួយលោកអ្នកឲ្យចេះសម្រេចចិត្តបានសមស្របទៅនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់។

៨. សូមបង្កើតសំណួរដែលនឹងជួយលោកអ្នកឲ្យយល់ដឹងពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដោយប្រើខគម្ពីរខាងក្រោមនេះ៖

១កូរិនថូស ៦:១២

១កូរិនថូស ៦:១៩-២០

១កូរិនថូស ៨:៩

១កូរិនថូស ១០:៣១

កាឡាទី ៦:៧-៨

ការដើរតាមព្រះយេស៊ូវ គឺដូចជាការដើរលើផ្លូវមួយ មិនមែនដូចជាការដើរលើខ្សែពួរទេ។ យើងត្រូវដើរតាមផ្លូវរបស់ព្រះយេស៊ូវដែលប្រកបដោយសេចក្តីស្រឡាញ់ ការបន្ទាបខ្លួន និងការគោរពប្រតិបត្តិដល់ព្រះវរបិតា ព្រមទាំងស្តាប់ព្រះសូរសៀងទ្រង់តាមរយៈការអធិស្ឋាន ដើម្បីស្វែងរកលំនាំដ៏ច្បាស់លាស់ពីទ្រង់។ ពេលខ្លះយើងឃើញថា ព្រះជាម្ចាស់ស្ងាត់ស្ងៀមចំពោះយើង ប៉ុន្តែក្នុងនាមទ្រង់ជាព្រះវរបិតារបស់យើង ទ្រង់សព្វព្រះហឫទ័យឲ្យយើងលូតលាស់តាមរយៈការសម្រេចចិត្តរបស់យើង។ ពេលខ្លះទៀតព្រះជាម្ចាស់បង្ហាញផ្លូវដល់យើងយ៉ាងច្បាស់៖ ទ្រង់ដឹកនាំយើងតាមរយៈព្រះបន្ទូលទ្រង់ដោយមានជំនួយមកពីព្រះវិញ្ញាណបរិសុទ្ធ។ នៅក្នុងលក្ខណៈបែបនេះ យើងនឹងក្លាយទៅជាមនុស្សដែលមានឆន្ទៈដ៏ខ្លាំងក្លា និងជាមនុស្សដែលចេះចុះចូលចំពោះព្រះជាម្ចាស់ ដោយគោរព និងស្រឡាញ់ព្រះជាម្ចាស់ ព្រមទាំងចេះបម្រើអ្នកដទៃផ្សេងទៀតដោយបន្ទាបខ្លួនផងដែរ។

## ការស្តាប់បង្គាប់ព្រះជាម្ចាស់

ប្រសិនបើលោកអ្នកបដិសេធទៅនឹងការស្តាប់បង្គាប់ព្រះជាម្ចាស់ចំពោះអ្វីដែលទ្រង់បានបង្ហាញលោកអ្នកទៅហើយនោះ តើគួរឲ្យទ្រង់បង្ហាញពីព្រះហឫទ័យរបស់ទ្រង់ដល់លោកអ្នកថែមទៀតដែរឬទេ? ការស្តាប់បង្គាប់ចំពោះព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលទ្រង់បានបើកសម្តែងរួចមកហើយនោះ គឺមានសារៈសំខាន់ ដើម្បីទទួលការដឹកនាំបន្ថែមទៀត។

៩. តើលោកអ្នកអាចយល់ពីព្រះហឫទ័យរបស់ព្រះជាម្ចាស់បានដោយរបៀបណា?

ទំនុកដំកើង ៣៧:៣១

ទំនុកដំកើង ១១៩:១០៥, ១៣០

១០. តើមានវិធីណាផ្សេងទៀតដែលលោកអ្នកអាចធ្វើ ដើម្បីឲ្យយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បាន?

ទំនុកដំកើង ១៤៣:៨

យ៉ាកុប ១:៥

១១. កណ្ឌគម្ពីរ ទំនុកដំកើង ២៥:៤-៥ គឺជាសេចក្ដីអធិស្ឋានមួយរបស់ស្ដេចដាវីឌ ស្ដីពីការស្វែងរកព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់ទ្រង់។ សូមសរសេរសេចក្ដីអធិស្ឋាននេះចេញពីគំនិតលោកអ្នកផ្ទាល់ ហើយប្រើវាទុកជាគំរូនៃការអធិស្ឋានមួយសម្រាប់លោកអ្នក។

១២. តើកណ្ឌគម្ពីររ៉ូម ១២:១-២ បានបញ្ជាក់ពីលក្ខខណ្ឌណាខ្លះ ដើម្បីឲ្យយើងអាចស្វែងរកព្រះហឫទ័យទ្រង់បាន?

១៣. តើព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើអ្វី នៅពេលដែលលោកអ្នកស្វែងរកការដឹកនាំមកពីព្រះជាម្ចាស់? (យ៉ូហាន ១៦:១៣)



១៤. សូមអានកណ្ឌគម្ពីរ អេសាយ ៣០:១៨។ បើតាមការយល់ឃើញរបស់លោកអ្នក សូមគិតទៅមើលថា ហេតុអ្វីបានជាពេលខ្លះព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យលោកអ្នករង់ចាំ មុននឹងទ្រង់សម្ដែងព្រះហឫទ័យរបស់ទ្រង់មកកាន់លោកអ្នក?

## ការបើកចំហដួងចិត្តដើម្បីទទួលការដឹកនាំពីព្រះជាម្ចាស់

លោកអ្នកអាចយកឈ្នះលើឧបសគ្គទាំងឡាយក្នុងការយល់ពីបំណងព្រះហឫទ័យព្រះជាម្ចាស់បាន គឺនៅពេលដែលលោកអ្នកបានត្រៀមខ្លួនរួចជាស្រេច ដើម្បីធ្វើតាមព្រះហឫទ័យរបស់ទ្រង់ ទោះបីជាព្រះអង្គសព្វព្រះហឫទ័យយ៉ាងណាក៏ដោយ។

១៥. លោកអ្នកមិនមែនតែងតែដឹងគ្រប់ទាំងការផ្សេងៗដែលអាចទៅរួច ដើម្បីកំណត់ថាលោកអ្នកត្រូវធ្វើយ៉ាងណានោះឡើយ។ តើអ្វីទៅជាមធ្យោបាយដែលលោកអ្នកអាចប្រើ ដើម្បីយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឲ្យកាន់តែច្បាស់? (សុភាសិត ១៥:២២)



លោកអ្នកគួរតែទទួលការប្រឹក្សាពីគ្រីស្ទបរិស័ទពេញវ័យដែលជាអ្នកប្តូរផ្តាច់ទៅនឹងបំណងព្រះហឫទ័យព្រះជាម្ចាស់ និងជាមនុស្សដែលស្គាល់លោកអ្នកយ៉ាងច្បាស់។ ប្រសិនបើលោកអ្នកចែកចាយជាមួយមនុស្សដែលធ្លាប់សម្រេចចិត្តក្នុងរឿងដូចដែលលោកអ្នកមាន នោះវានឹងជួយលោកអ្នកឲ្យដើរតាមព្រះហឫទ័យរបស់ទ្រង់។

១៦. សូមពន្យល់ពីគោលការណ៍ដែលព្រះយេស៊ូវប្រើក្នុងការឆ្លើយសំណួរអ្នកដែលបានសួរទ្រង់នៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ៧:១៧។

តើគោលការណ៍នេះជួយលោកអ្នកឲ្យស្គាល់ព្រះហឫទ័យព្រះជាម្ចាស់បានយ៉ាងដូចម្តេច?

១៧. នៅពេលដែលលោកអ្នកដឹងពីអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យលោកអ្នកធ្វើ តើលោកអ្នកគួរតែធ្វើវាយ៉ាងដូចម្តេច? (អេភេសូរ ៦:៦)

១៨. តើមានកត្តាណាផ្សេងទៀតដែលអាចជួយលោកអ្នកឲ្យយល់នូវការដឹកនាំរបស់ព្រះជាម្ចាស់កាន់តែច្បាស់?

រ៉ូម ១៣:១

អេភេសូរ ៥:១៥-១៧

កូល៉ុស ៣:១៥

*ដូចដែលយើងបានឃើញរួចមកហើយថា ការត្រាស់ហៅរបស់ព្រះគ្រីស្ទមានន័យថា យើងត្រូវមកតាមទ្រង់។ ខ្លឹមសារសំខាន់នៃការត្រាស់ហៅនោះ គឺផ្តោតលើការផ្លាស់ប្តូរទិសដៅរបស់យើង ដើម្បីតាមទ្រង់។*

លោកបណ្ឌិត យ៉ូសែប ស្តូវែល (Dr. Joseph Stowell)
ដកស្រង់ចេញពីសៀវភៅ *Following Christ*

# ការអនុវត្តគោលការណ៍

តារាងខាងក្រោមនេះអាចជួយលោកអ្នកឲ្យយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ក្នុងការសម្រេចចិត្តដែលលោកអ្នកកំពុងតែប្រឈមមុខ។

សូមសរសេរពីការសម្រេចចិត្តដែលលោកអ្នកកំពុងប្រឈមមុខ៖

| គោលបំណងនៃបទគម្ពីរ | មែន | មិនមែន | មិនប្រាកដ |
|---|---|---|---|
| តើខ្ញុំកំពុងតែដាក់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សំខាន់ជាងបំណងរបស់ខ្ញុំដែរឬទេ? | | | |
| តើការនេះនឹងជួយខ្ញុំឲ្យស្រឡាញ់ព្រះជាម្ចាស់ និងអ្នកដទៃកាន់តែខ្លាំងថែមទៀតដែរឬទេ? | | | |
| តើការនេះនឹងជួយឲ្យខ្ញុំបំពេញមហាបេសកកម្មបានដែរឬទេ? | | | |
| តើការនេះនឹងជួយឲ្យខ្ញុំរស់នៅកាន់តែបរិសុទ្ធ ហើយមានចិត្តមេត្តាដែរឬទេ? | | | |
| តើការនេះនឹងចម្រើនភាពស្និទ្ធស្នាល និងការថ្វាយបង្គំរបស់ខ្ញុំចំពោះព្រះជាម្ចាស់ដែរឬទេ? | | | |
| សំណួរផ្សេងៗ៖ | | | |

## ការស្តាប់បង្គាប់ព្រះជាម្ចាស់

១៩. តើថ្មីៗនេះខ្ញុំបានឃើញអ្វីខ្លះ នៅក្នុងបទគម្ពីរដែលទាក់ទងទៅនឹងការសម្រេចចិត្តនេះ?

២០. តើខ្ញុំបានអធិស្ឋានអំពីការសម្រេចចិត្តនេះហើយឬនៅ?

## ការបើកចំហដួងចិត្តដើម្បីទទួលយកការដឹកនាំរបស់ព្រះជាម្ចាស់

២១. តើមានជម្រើសអ្វីខ្លះដែលខ្ញុំអាចជ្រើសរើសនៅក្នុងការសម្រេចចិត្តនេះ?

| ជម្រើស | គុណសម្បត្តិ | គុណវិបត្តិ |
| --- | --- | --- |
| | | |

២២.តើខ្ញុំពិតជាសុខចិត្តធ្វើនូវអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យខ្ញុំធ្វើដែរឬទេ?

២៣.តើខ្ញុំបានទទួលការប្រឹក្សាបែបណាខ្លះពីអ្នកដទៃផ្សេងទៀត?

២៤. តើខ្ញុំមានបំណងប្រាថ្នាដែលមិនត្រឹមត្រូវណាខ្លះ?

២៥. តើខ្ញុំខ្លាចថាទ្រង់នឹងឲ្យខ្ញុំធ្វើអ្វីដែលខ្ញុំមិនចង់ធ្វើដែរឬទេ?

២៦. តើជម្រើសមួយណាដែលខ្ញុំដឹងនៅក្នុងវិញ្ញាណរបស់ខ្ញុំថាជាជម្រើសដ៏ត្រឹមត្រូវ?

២៧.តើមានកាលៈទេសៈអ្វីខ្លះ ដែលជាប់ទាក់ទងទៅនឹងការសម្រេចចិត្តនេះ?

# សំណើខគម្ពីរមួយសម្រាប់ការ សញ្ជឹងគិត និងការទន្ទេញចាំមាត់



ភីលីព ២:១៣

ដ្បិតគឺជាព្រះហើយ ដែលបណ្ដាលចិត្តអ្នករាល់គ្នា ឲ្យមានទាំងចំណង់ចង់ធ្វើ ហើយឲ្យបានប្រព្រឹត្តតាមបំណងព្រះហឫទ័យទ្រង់ដែរ

ភីលីព ២:១៣

# សៀវភៅកំណត់ហេតុរបស់ខ្ញុំ

ឥឡូវសូមងាកទៅមើលកណ្ឌគម្ពីរ យេរេមា ២៩:១១ និងអេភេសូរ ២:១០ ឡើងវិញ។ ដោយយោងតាមសេចក្ដីស្រឡាញ់ ភាពស្មោះត្រង់ និងការមានបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ចំពោះលោកអ្នក តើសេចក្ដីសង្ឃឹមរបស់លោកអ្នកសម្រាប់ថ្ងៃអនាគតនោះគឺជាអ្វី? តើលោកអ្នកគិតថា ការល្អដែលព្រះជាម្ចាស់រៀបចំឲ្យលោកអ្នកធ្វើនោះគឺជាអ្វី?

# ចំណុចគួរចងចាំ

- ព្រះជាម្ចាស់បានបើកសម្ដែងពីបំណងព្រះហឫទ័យ គុណតម្លៃ និងគោលដៅរបស់ទ្រង់សម្រាប់យើងយ៉ាងច្បាស់។
- នៅក្នុងការសម្រេចចិត្ត យើងត្រូវស្វែងរកព្រះជាម្ចាស់ជាជាងសេចក្ដីប្រាថ្នាចង់បានរបស់យើង ដើម្បីស្វែងយល់ពីបំណងព្រះហឫទ័យដ៏ជាក់លាក់របស់ព្រះជាម្ចាស់សម្រាប់យើងបាន។
- ការមានបំណងចិត្តរួចជាស្រេច និងការបើកចំហចិត្តក្នុងការដើរតាមព្រះជាម្ចាស់កើតមុនការរកឃើញផ្លូវដ៏ពិតប្រាកដមួយ។
- ការសួរសំណួរល្អៗ (ដូចជាសំណួរដែលមាននៅក្នុងជំពូកមេរៀននេះ) នៅពេលដែលយើងចូលមកចំពោះព្រះជាម្ចាស់គឺជាជំនួយដ៏មានប្រសិទ្ធភាពមួយឆ្ពោះទៅមុខទៀត។

# ការចូលឲ្យបានស៊ីជម្រៅ

**សូមជ្រើសរើសយកជម្រើស “ក” ឬក៏ជម្រើស “ខ”**

**ជម្រើស ក៖** នៅសម័យកាលរបស់ហោរា យេរេមា ព្រះជាម្ចាស់បានអនុញ្ញាតឲ្យស្តេច នេប៊ូក្នេសា ដែលមិនមែនជាអ្នកជឿលើព្រះជាម្ចាស់នោះចេញទៅច្បាំងនឹងប្រជាជាតិរបស់ព្រះជាម្ចាស់ ហើយដឹកនាំពួកគេទៅបាប៊ីឡូនទុកជាឈ្លើយ។ ពួកគេពិបាកយល់ថា ការនិរទេសជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ពួកគេ។ សូមអានការពន្យល់បកស្រាយរបស់ព្រះជាម្ចាស់ពីបំណងព្រះហឫទ័យរបស់ទ្រង់នៅក្នុងកណ្ឌគម្ពីរ យេរេមា ២៩:៤-១៤។

ក) តើពួកគេត្រូវរង់ចាំអស់រយៈពេលយូរប៉ុណ្ណាមុននឹងព្រះជាម្ចាស់រំដោះពួកគេឲ្យរួច? (ខ១០)

ខ) ទន្ទឹមនឹងនេះដែរ តើព្រះជាម្ចាស់បានមានបន្ទូលឲ្យពួកគេរស់នៅយ៉ាងដូចម្តេច? (ខ៥-៧)

គ) តើព្រះជាម្ចាស់បានពណ៌នាពីគម្រោងផែនការ និងពីបំណង ព្រះហឫទ័យរបស់ទ្រង់ចំពោះពួកគេយ៉ាងដូចម្ដេច? (ខ១១)

ឃ) តើព្រះជាម្ចាស់បានសន្យាអ្វីខ្លះចំពោះពួកគេ ប្រសិនបើពួកគេស្វែងរកទ្រង់នោះ? (ខ១២-១៤)

ង) តើលោកអ្នករកឃើញអ្វីខ្លះ ពីបំណងព្រះហឫទ័យរបស់ទ្រង់ចេញពីរឿងនេះ?

**ជម្រើស ខ៖ រូបភាពដែលបង្ហាញពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់**
រូបភាពខាងក្រោមនេះមិនមែនជាទម្រង់នៃការសម្រេចលើបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ក្នុងស្ថានភាពជាក់លាក់ណាមួយនោះទេ។ ប៉ុន្តែរូបនេះបង្ហាញពីផ្នែកមួយចំនួន ដើម្បីឲ្យយើងយកមកពិចារណាក្នុងការសម្រេចចិត្ត។



១. **ការប្ដេជ្ញាចិត្ត៖** រ៉ូម ១២:១

- ការប្ដេជ្ញាចិត្តមិនមែនធ្វើត្រឹមតែចំពោះភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទប៉ុណ្ណោះនោះទេ ប៉ុន្តែរួមទាំងអ្វីៗដែលទ្រង់នឹងសម្ដែងមកជាផ្លូវរបស់ទ្រង់។ យើងមិនអាចនិយាយថា "ព្រះជាម្ចាស់អើយ សូមបង្ហាញបំណងព្រះហឫទ័យទ្រង់ឲ្យទូលបង្គំបានឃើញ ហើយប្រសិនបើទូលបង្គំពេញចិត្ត នោះទូលបង្គំនឹងធ្វើវានោះទេ"។ (សូមអានកណ្ឌគម្ពីរ លូកា ៦:៤៦៖ "ហេតុអ្វីបានជាហៅខ្ញុំថា ឱព្រះអម្ចាស់ៗអើយ តែមិនធ្វើតាមពាក្យខ្ញុំវិញដូច្នេះ?")

២. **ការបញ្ជា៖** (ព្រះបន្ទូលព្រះជាម្ចាស់សម្ដែងពីព្រះហឫទ័យទ្រង់)
ទំនុកដំកើង ១១៩:១០៥

- បញ្ញត្តិដែលបង្ហាញពីបំណងព្រះហឫទ័យរបស់ទ្រង់យ៉ាងច្បាស់លាស់ក្នុងស្ថានភាពជាច្រើន។
- គោលការណ៍ដែលបង្ហាញពីប្រព័ន្ធនៃគុណតម្លៃ និងវិធីសាស្ត្ររបស់ព្រះជាម្ចាស់។
- សេចក្ដីសន្យានៅក្នុងបទគម្ពីរបានផ្ដល់នូវទិសដៅនៅក្នុងព្រឹត្តិការណ៍ដែលកើតមានឡើងមួយចំនួន។

៣. **ការទទួលយោបល់៖** សុភាសិត ១២:១៥, ១៥:២២

- គឺជាការផ្ដល់យោបល់ពីនរណាម្នាក់អំពីជីវិតរបស់លោកអ្នក ហើយជាការដែលលោកអ្នកផ្ដល់យោបល់ដល់អ្នកដទៃផ្សេងទៀត នោះមានន័យថា យើងកំពុងតែទទួលយក ហើយនិងផ្ដល់នូវទំនុកចិត្តដល់គ្នាទៅវិញទៅមក។
- គឺជាការការពារពីការសម្រេចចិត្តដោយងងឹតងងល់ និងការធ្វើតាមតែចិត្តមានះ ព្រមទាំងការធ្វេសប្រហែស។
- ការណែនាំក្នុងការស្វែងរកយោបល់ពីអ្នកប្រឹក្សា៖

  **ក) លក្ខណៈរបស់អ្នកប្រឹក្សា**

  - ជាអ្នកដែលប្រសប់ខាងការសម្រេចចិត្ត
  - ជាអ្នកដែលបង្ហាញពីដួងចិត្តសម្រាប់ព្រះជាម្ចាស់
  - ជាអ្នកដែលស្គាល់លោកអ្នកច្បាស់លាស់ ឬក៏ស្គាល់លោកអ្នកល្មម

ខ) **ដំណើរការ៖** កុំគ្រាន់តែស្វែងរកយោបល់ពីនរណាម្នាក់ដែលយល់ស្រប ជាមួយលោកអ្នកនោះឡើយ។

គ) **លទ្ធផល៖** កុំគ្រាន់តែសម្រេចចិត្តដោយផ្អែកតែទៅលើអ្វីដែលអ្នកដទៃ មានប្រសាសន៍នោះឡើយ។

៤. **កាលៈទេសៈ៖** ភីលីព ១:១២-១៣

- នៅពេលដែលព្រះជាម្ចាស់បិទផ្លូវណាមួយមិនឲ្យសាវ័ក ប៉ុល ចូលនោះ ទ្រង់តែងតែបើកផ្លូវផ្សេងទៀតឲ្យគាត់។ ប៉ុន្តែទោះបីជាផ្លូវនោះអាចទៅបាន ក៏ដោយ ក៏មិនមែនមានន័យថា បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់មាន តែប៉ុណ្ណោះនោះទេ។
- ព្រះជាម្ចាស់មិនបណ្ដាលឲ្យកើតមានកាលៈទេសៈ ដែលបង្ហាញពី ព្រះហឫទ័យរបស់ទ្រង់រៀងរាល់ពេលវេលានោះទេ។ យើងមិនអាចយក ព្រះជាម្ចាស់មកធ្វើជាអ្នកដែលយើងទាមទាររកហេតុផលឲ្យទ្រង់បញ្ជាក់ពី បំណងព្រះហឫទ័យរបស់ទ្រង់តាមកាលៈទេសៈទាំងឡាយនោះបានទេ។
- ព្រះជាម្ចាស់បានអនុញ្ញាតឲ្យសាតាំងមានអំណាចលើកាលៈទេសៈមួយ ចំនួន (យ៉ូប ១-២)។ ការដើរតាមព្រះជាម្ចាស់យ៉ាងប្រកៀក គឺជាគន្លឹះដែល ជួយបង្ហាញឲ្យលោកអ្នកយល់ថា តើកាលៈទេសៈមួយណាមកពីទ្រង់។
- លោកអ្នកអាចយល់បានថា កាលៈទេសៈមួយណាមកពីទ្រង់ដោយសារៈ អំណោយទាន សមត្ថភាព និងអ្វីៗដែលចិត្តរបស់លោកអ្នកចង់ធ្វើ ពីព្រោះ ទ្រង់បានបង្កើតលោកអ្នកតាមបែបនោះឯង។

៥. **ភាពស្ងប់ស្ងាត់៖** កូល៉ុស ៣:១៥

- នៅពេលដែលយើងចង់ស្វែងរកព្រះហឫទ័យរបស់ព្រះជាម្ចាស់តាមរយៈ ការអធិស្ឋាន នោះយើងអាចយល់ក្នុងវិញ្ញាណយ៉ាងច្បាស់ថា ផ្លូវមួយណា ដែលល្អបំផុតសម្រាប់យើង។
- ភាពស្ងប់ស្ងាត់ដាច់ខាតត្រូវតែពឹងផ្អែកទៅលើការធានាដែលថា ព្រះជាម្ចាស់ កំពុងតែដឹកនាំលោកអ្នក មិនមែនពឹងផ្អែកទៅលើបំណងចិត្តខាង សាច់ឈាមដែលចង់តែតាមផ្លូវស្រួលនោះទេ។ (សុភាសិត ៣:៥-៦)

ជំពូកទី

# ៥

# ការដើរក្នុងនាមជាអ្នកបម្រើ

មនុស្សគ្រប់រូបមានភាពសប្បាយរីករាយណាស់ក្នុងការដែលឲ្យអ្នកដទៃបម្រើខ្លួន ប៉ុន្តែមានភាគតិចណាស់ដែលសប្បាយរីករាយក្នុងការបម្រើអ្នកដទៃវិញ។ មនុស្សជាទូទៅមិនប្រកាន់ទេដោយគ្រាន់តែគេហៅខ្លួនថាជាអ្នកបម្រើ ប៉ុន្តែពួកគាត់ពិតជាប្រកាន់ណាស់នៅពេលមាននរណាម្នាក់ប្រើគាត់ដូចជាអ្នកបម្រើ។ គេអាចកត់សម្គាល់គ្រីស្ទបរិស័ទពេញវ័យបានដោយសារទង្វើដែលគាត់ប្រព្រឹត្តចំពោះអ្នកដទៃ ដោយគាត់មិនរំពឹងថានឹងទទួលការតបស្នងមកវិញនៅថ្ងៃក្រោយនោះទេ។

# ព្រះគ្រីស្ទជាគំរូរបស់លោកអ្នក



១. តើព្រះគ្រីស្ទយាងមកផែនដីនេះក្នុង
គោលបំណងអ្វី? (ម៉ាកុស ១០:៤៥)

តើព្រះយេស៊ូវបម្រើមនុស្សដោយរបៀបណាខ្លះ? (ម៉ាថាយ ៩:៣៥)

*“មនុស្សទូទៅបានជឿយ៉ាងខ្លាំងថា បើគេប្រមូលទ្រព្យសម្បត្តិបានច្រើននោះមានន័យថា គេមានជ័យជម្នះហើយ ប៉ុន្តែព្រះយេស៊ូវបានមានបន្ទូលចំពោះពួកគេថា “ដ្បិតបើមនុស្សណានឹងបានលោកីយ៍ទាំងមូល តែបាត់ព្រលឹងទៅ នោះតើមានប្រយោជន៍អ្វីដល់អ្នកនោះ?” (ម៉ាថាយ ១៦:២៦)។ ព្រះគ្រីស្ទបានបង្រៀនថា របៀបដែលលោកអ្នកអាចទទួលបានអ្វីមួយនោះគឺ លោកអ្នកត្រូវឲ្យអ្វីមួយនោះទៅគេជាមុនសិន។ ការលះកាត់ចិត្តខ្លួនឯងគឺជាគន្លឹះដែលនាំឲ្យមានជីវិត។ យើង*

*អាចទទួលបានភាពឧត្តុង្គឧត្តមតាមរយៈការបម្រើអ្នកដទៃ។ យើងមិនគួរឲ្យតម្លៃទៅលើភាពឯករាជ្យនោះទេ ប៉ុន្តែយើងគួរតែឲ្យតម្លៃទៅលើការចុះចូលចំពោះព្រះយេស៊ូវក្នុងនាមជាអ្នកដើរតាមដែលស្តាប់ចិត្ត ហើយធ្វើជាអ្នកបម្រើដ៏មានប្រយោជន៍ព្រមទាំងជាអ្នកបម្រើដែលព្រះជាម្ចាស់អាចប្រើបាន។*

លោកបណ្ឌិត យ៉ូសែប ស្តូវែល (Dr. Joseph Stowell)
ដកស្រង់ចេញពីសៀវភៅ *Following Christ*

២. សូមអានកណ្ឌគម្ពីរ យ៉ូហាន ១៣:១-៥, ១៤-១៥។

ក) យោងតាមខ៤-៥ តើព្រះយេស៊ូវបានបម្រើសិស្សរបស់ទ្រង់ដោយរបៀបណា?

ខ) ហេតុអ្វីបានជាព្រះយេស៊ូវមិនខ្មាសក្នុងការធ្វើកិច្ចការដ៏តូចទាបដូច្នេះ? (ខ៣)

គ) ហេតុអ្វីបានជាទ្រង់បម្រើពួកសិស្សបែបយ៉ាងនេះ? (ខ១, ១៤-១៥)



ឃ) តើលោកអ្នកអាចអនុវត្តអ្វីខ្លះចេញពីអត្ថបទនេះ?

៣. សូមអានកណ្ឌគម្ពីរ ភីលីព ២:៥-១១។

ក) តើព្រះគ្រីស្ទបានលះបង់អ្វី? ហើយតើទ្រង់បានយកឋានៈជាអ្វី? (ខ៦-៧)

ខ) តើទ្រង់បានបង្ហាញពីភាពជាបាវបម្រើដោយរបៀបណា? (ខ៧-៨)

គ) តាមការយល់ឃើញរបស់លោកអ្នក តើនៅក្នុងព្រះហឫទ័យរបស់ព្រះយេស៊ូវ ទ្រង់កំពុងតែបម្រើនរណា?

ឃ) តើព្រះជាម្ចាស់បានប្រទានរង្វាន់ដល់ព្រះយេស៊ូវពីការបម្រើដោយបន្ទាបខ្លួនដោយរបៀបណា និងនៅពេលណា? (ខ៨-១១)

៤. សូមគិតមើល ព្រះយេស៊ូវបានបម្រើដល់មនុស្សគ្រប់ប្រភេទ សូម្បីតែមនុស្សដែលក្បត់នឹងទ្រង់ក៏ដោយ។ តើមានមនុស្សណាខ្លះដែលលោកអ្នកពិបាកបម្រើបំផុត? តើលោកអ្នកមានអារម្មណ៍យ៉ាងណាក្នុងការបម្រើពួកគេ? តើមានការជាក់លាក់បែបណាដែលលោកអ្នកអាចធ្វើ ដើម្បីបម្រើពួកគេបាន?



## ព្រះហឫទ័យរបស់ព្រះគ្រីស្ទសម្រាប់លោកអ្នក

៥. សូមឆ្លុះបញ្ចាំងទៅលើសេចក្ដីណែនាំរបស់ព្រះជាម្ចាស់នៅក្នុងកណ្ឌគម្ពីរភីលីព ២:៣-៥។

ក) តើបទគម្ពីរត្រង់នេះ បានប្រាប់លោកអ្នកឲ្យធ្វើអ្វីខ្លះ?

ខ) តើលោកអ្នកមានអារម្មណ៍ដូចម្ដេច នៅពេលដែលមានគេរាប់លោកអ្នកដូចជាអ្នកបម្រើ? តើលោកអ្នកមានដំណោះស្រាយយ៉ាងណាពីអារម្មណ៍ទាំងនេះ?

គ) សូមគិតពីស្ថានភាពដែលលោកអ្នកប្រព្រឹត្តចេញមកពី "មហិច្ឆតាដ៏អាត្មានិយម ឬក៏អំនួតដែលឥតប្រយោជន៍" ជាជាងការគិតទៅលើ "អ្នកដទៃលើសជាងខ្លួន"។ សូមសរសេរពីស្ថានភាពនោះ៖



ស្ង នឹងអ្នកដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យលោកអ្នកបម្រើដោយបន្ទាបខ្លួន ទោះបីជាវាមានន័យថា លោកអ្នកត្រូវតែដកចំណាប់អារម្មណ៍ផ្ទាល់ខ្លួនចេញ ហើយដាក់ចំណាប់អារម្មណ៍របស់អ្នកផ្សេងជំនួសក៏ដោយ។ សូមសរសេរពីរបៀបដែលព្រះជាម្ចាស់បង្ហាញលោកអ្នកឲ្យបម្រើនៅក្នុងតារាងទំព័របន្ទាប់។

៦. សូមសម្គាល់ពីមនុស្សដែលលោកអ្នកគួរបម្រើ និងគោលការណ៍ផ្សេងៗនៃការបម្រើដែលបានលើកឡើងពីខគម្ពីរនីមួយៗនៅក្នុងតារាងខាងក្រោម៖

| ខគម្ពីរ | មនុស្សដែលលោកអ្នកគួរបម្រើ | គោលការណ៍នៃការបម្រើ |
| --- | --- | --- |
| យ៉ូហាន ១២:២៦ | | |
| កាឡាទី ៥:១៣ | | |
| កាឡាទី ៦:៩-១០ | | |

៧. អំឡុងពេលពិធីជប់លៀងចុងក្រោយរបស់ព្រះគ្រីស្ទជាមួយនឹងសិស្សរបស់ទ្រង់មុននឹងទ្រង់សុគត ព្រះយេស៊ូវបានស្រាយបំភ្លឺពីអត្តចរិតមួយចំនួនក្នុងការបម្រើ។ សូមអានកណ្ឌគម្ពីរ លូកា ២២:២៤-២៧។

ក) តើពួកសិស្សបានប្រកែកគ្នាអំពីរឿងអ្វី? (ខ២៤)

ខ) តើអ្នកដែលដើរតាមព្រះគ្រីស្ទគួររស់នៅដោយរបៀបណា? (ខ២៦)

គ) តើរបៀបនៃការរស់នៅរបស់អ្នកដើរតាមព្រះយេស៊ូវ ខុសពីរបៀបនៃការរស់នៅរបស់លោកីយ៍យ៉ាងដូចម្ដេចខ្លះ? (ខ២៥)

> *អ្នកដើរតាមព្រះគ្រីស្ទយ៉ាងអស់ពីចិត្ត គឺជាអ្នកដែលបំពេញកិច្ចការរបស់ទ្រង់ ហើយពួកគេជាអ្នកដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងទ្រង់ ដោយពួកគេរាប់ខ្លួនជាអ្នកបម្រើដល់អ្នកដទៃ ប្រយោជន៍នឹងបំពេញបំណងព្រះហឫទ័យដ៏អស់កល្បរបស់ព្រះគ្រីស្ទ។ យើងមិនគួរភ្លេចពីការពិតដែលព្រះនៃសកលលោកបានប្រសូតមកជាមនុស្ស ហើយទ្រង់បានជ្រើសរើសយករូបភាពជាបាវបម្រើនោះឡើយ (ភីលីព ២:៥-១១)។ នេះគឺជាការដ៏គួរឲ្យភ្ញាក់ផ្អើលមែនទែនដែលថា ទ្រង់បានជ្រើសរើសយកភាពជាបាវបម្រើលើសពីលក្ខណសម្បត្តិផ្សេងទៀតដែលទ្រង់អាចយកមកបាន ដើម្បីប្រទានកម្លាំងឲ្យយើងអាចលូតលាស់រហូតដល់មានសិរីរុងរឿង។*
>
> លោកបណ្ឌិត យ៉ូសែប ស្ដូវែល (Dr. Joseph Stowell)
> ដកស្រង់ចេញពីសៀវភៅ *Following Christ*

# ការថ្វាយខ្លួន

ព្រះជាម្ចាស់បានរំដោះអ្នកជឿគ្រប់ៗគ្នាឲ្យមានសេរីភាពក្នុងព្រះគ្រីស្ទ មិនមែនឲ្យពួកគេទៅធ្វើអ្វីតាមតែចិត្តនោះទេ ប៉ុន្តែឲ្យមកបម្រើវិញ។ អ្នកដើរតាមព្រះយេស៊ូវមិននៅបម្រើនិស្ស័យចាស់ទៀតឡើយ ប៉ុន្តែពួកគេមានសេរីភាពក្នុងការបម្រើខាងឯនិស្ស័យថ្មីដោយស្ម័គ្រចិត្តវិញ។

៨. យោងតាមបទគម្ពីរខាងក្រោមនេះ តើព្រះយេស៊ូវសង្គ្រោះពួកយើងចេញពីអ្វី ឬក៏ពីនរណា? ដោយព្រោះព្រះគ្រីស្ទបានសង្គ្រោះយើង តើយើងមានសេរីភាពបម្រើអ្វី ឬក៏បម្រើនរណាវិញ?

| ខគម្ពីរ | ទ្រង់រំដោះយើងឲ្យរួចពី... | ដើម្បីបម្រើ... |
|---|---|---|
| រ៉ូម ៦:១៨-១៩ | | |
| ១ពេត្រុស ២:១៦ | | |
| កាឡាទី ៥:១៣ | | |

៩. តើសាវ័ក ប៉ុល រាប់ខ្លួនឯងថាជាអ្វី? (២កូរិនថូស ៤:៥)

តើសាវ័ក ប៉ុល បានសម្ដែងពីអត្តសញ្ញាណក្នុងនាមជាអ្នកបម្រើម្នាក់ ដោយរបៀបណាខ្លះ? (២កូរិនថូស ១២:១៥)

## គន្លឹះនៃភាពជាអ្នកបម្រើ

### ការបន្ទាបខ្លួន

១០. តើមានអ្វីដែលលោកអ្នកត្រូវតែនឹកចាំក្នុងចិត្តជានិច្ច? (យ៉ូហាន ១៣:១៣, ១៦)

១១. ក្នុងនាមជាអ្នកបម្រើម្នាក់ លោកអ្នកអាចមានអំនួតពីការបម្រើនោះ។ តើមានអ្វីខ្លះដែលអាចរារាំងលោកអ្នកមិនឲ្យមានអំនួត? (លូកា ១៧:១០)



## ការសង្កេតនិងការផ្គត់ផ្គង់តម្រូវការរបស់អ្នកដទៃ

១២. អ្នកបម្រើ គឺជាអ្នកដែលចេះសង្កេតមើល។ «ការស្តាប់ឮដោយត្រចៀក ហើយមើលឃើញដោយភ្នែក នោះគឺព្រះយេហូវ៉ា ដែលបង្កើតទាំង២យ៉ាង» (សុភាសិត ២០:១២)។ ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យលោកអ្នកប្រើត្រចៀក និងភ្នែកដែលទ្រង់បានប្រទានមកដើម្បីស្តាប់ ហើយនិងសង្កេតមើល។

ក) តើលោកអ្នកអាចក្លាយជាអ្នកស្តាប់ដ៏ល្អម្នាក់ដោយរបៀបណា?

ខ) តើលោកអ្នកអាចក្លាយជាអ្នកសង្កេតមើលដ៏ល្អម្នាក់ដោយរបៀបណា?

១៣. តើមានការអនុវត្តបែបណាខ្លះ ដែលលោកអ្នកអាចយកមកជួយដល់តម្រូវការរបស់អ្នកដទៃផ្សេងទៀតបាន?

សុភាសិត ៣:២៧

ម៉ាថាយ ២៥:៣៥-៣៦

១យ៉ូហាន ៣:១៧

១៤. ចូរពិចារណាទៅលើក្រុមមនុស្សខាងក្រោមដោយភ្ជាប់ជាមួយនឹងសំណួរផ្សេងៗដែលលោកអ្នកបានឆ្លើយពីមុន។ តើលោកអ្នកអាចបម្រើពួកគេដោយរបៀបណានៅក្នុងសប្តាហ៍នេះ?

- ឪពុកម្តាយ
- បងប្អូន
- មិត្រភក្តិ
- និយោជក

- លោកគ្រូ អ្នកគ្រូ
- និយោជិក
- ខ្មាំងសត្រូវ
- អ្នកដឹកនាំខាងព្រលឹងវិញ្ញាណ

## ការឲ្យ

វិធីរូបិយមួយដែលល្អ ដើម្បីបម្រើអ្នកដទៃនោះ គឺការជួយផ្គត់ផ្គង់តម្រូវការរបស់ពួកគេទាំងខាងប្រាក់កាក់ និងសម្ភារៈ។ ប្រសិនបើលោកអ្នកមានបំណងចិត្តដើម្បីផ្តល់នូវអ្វីដែលជារបស់រូបិយ នោះលោកអ្នកនឹងកាន់តែចង់ផ្តល់នូវអ្វីដែលអរូបិយផងដែរ ដូចជា ពេលវេលា បទពិសោធន៍ សេចក្តីស្រឡាញ់ និងជីវិតរបស់លោកអ្នកផ្ទាល់។

១៥. យោងតាមព្រះគម្ពីរសញ្ញាថ្មី តើមានគោលការណ៍ និងសេចក្តីសន្យាអ្វីខ្លះដែលផ្តល់នូវមូលដ្ឋានគ្រឹះស្តីពីការផ្គត់ផ្គង់?

២កូរិនថូស ៨:៩

២កូរិនថូស ៩:៦

២កូរិនថូស ៩:៨

ភីលីព ៤:១៩



១៦. ការជំរុញចិត្តរបស់យើងគឺជាការសំខាន់ណាស់ក្នុងការដែលយើងផ្តត់ផ្គង់គេ។ ការជំរុញចិត្តដ៏ល្អមិនមែនស្តីពីកាតព្វកិច្ចនោះទេ ប៉ុន្តែវាជាចិត្តនៃការថ្វាយបង្គំព្រះជាម្ចាស់ និងជាក្តីស្រឡាញ់។ សូមសញ្ជឹងគិតលើកណ្ឌគម្ពីរ យ៉ូហាន ១២:១-៧។

ក) តើមានអ្វីជំរុញចិត្តម៉ារាឲ្យចេះផ្តល់ឲ្យ?

ខ) តើជាទូទៅ មានអ្វីជំរុញចិត្តលោកអ្នកឲ្យចេះផ្តល់ឲ្យ?

គ) ប្រសិនបើការជំរុញចិត្តរបស់លោកអ្នកមិនត្រឹមត្រូវ តើការនោះគួរនឹងបង្ខាំងលោកអ្នកក្នុងការផ្តល់ឲ្យដែរឬទេ? សូមពន្យល់៖

១៧. យោងទៅតាមខគម្ពីរនៅក្នុងតារាងខាងក្រោមនេះ តើលោកអ្នកតែគួរឲ្យទៅនរណា? សូមសរសេរឈ្មោះមនុស្សដ៏ជាក់លាក់ម្នាក់ដែលលោកអ្នកគួរឲ្យ នៅក្នុងខនីមួយៗខាងក្រោម៖

| ខគម្ពីរ | ប្រភេទមនុស្សដែលខ្ញុំគួរឲ្យ... | ឈ្មោះអ្នកដែលខ្ញុំអាចឲ្យ... |
| --- | --- | --- |
| សុភាសិត ១៩:១៧ | | |
| ១កូរិនថូស ៩:១៤ | | |
| កាឡាទី ៦:៦ | | |
| យ៉ាកុប ២:១៥-១៦ | | |

១៨. សូមវាយតម្លៃលើការផ្តល់ឲ្យរបស់លោកអ្នកដោយឆ្លើយសំណួរទាំងបីខាងក្រោមនេះ៖

ក) តើលោកអ្នកមានគម្រោងក្នុងការផ្តល់ឲ្យហើយឬនៅ?

ខ) តើឥឡូវនេះ លោកអ្នកកំពុងឲ្យទៅនរណា?

គ) តើលោកអ្នកត្រូវការប្តូររបៀបក្នុងការផ្តល់ឲ្យរបស់លោកអ្នកខ្លះដែរ ឬទេ? ប្រសិនបើត្រូវការ តើលោកអ្នកនឹងប្តូរដោយរបៀបណាខ្លះ?

## សំណើខគម្ពីរមួយសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់



ភីលីព ២:៥-៧

ត្រូវតែមានគំនិតគិតដូចជាព្រះគ្រីស្ទយេស៊ូវវិញ ដែលទោះបើទ្រង់មានរូបអង្គជាព្រះក៏ដោយ គង់តែមិនបានរាប់សេចក្តីស្មើនឹងព្រះនោះ ទុកជាសេចក្តីដែលគួរកាន់ខ្ជាប់ឡើយ គឺទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជាបាវបំរើវិញ ព្រមទាំងប្រសូតមកមានរូបជាមនុស្សផង

ភីលីព ២:៥-៧

# សៀវភៅកំណត់ហេតុរបស់ខ្ញុំ

តើព្រះយេស៊ូវបានបម្រើលោកអ្នកយ៉ាងដូចម្ដេចដែរនៅសប្ដាហ៍នេះ? តើលោកអ្នកបានបម្រើព្រះយេស៊ូវ និងអ្នកដទៃទៀតយ៉ាងដូចម្ដេចដែរនៅសប្ដាហ៍នេះ?

## ចំណុចគួរចងចាំ

- មិនមាននរណាម្នាក់បានបង្ខំព្រះយេស៊ូវគ្រីស្ទឲ្យធ្វើជាអ្នកបម្រើនោះទេ ប៉ុន្តែទ្រង់ធ្វើដោយស្ម័គ្រព្រះទ័យ គឺលះបង់អង្គទ្រង់ផ្ទាល់ ដើម្បីបំពេញតម្រូវការរបស់មនុស្ស។
- ព្រះគ្រីស្ទបានជួយដល់អ្នកជឿទ្រង់ទាំងអស់ ដូច្នេះពួកគេគួរតែតបស្នងដោយបម្រើទ្រង់ និងបម្រើអ្នកដទៃផ្សេងទៀតផងដែរ។
- អ្នកជឿត្រូវតែ «ស្លាប់ខាងឯសាច់ឈាម» ដើម្បីរស់នៅសម្រាប់អ្នកដទៃវិញ។ នៅពេលនោះពួកគេនឹងមានសេរីភាពក្នុងការធ្វើជាអ្នកបម្រើ។
- អ្នកបម្រើត្រូវតែបន្ទាបខ្លួន ហើយចេះសង្កេតមើលទាំងការតូចនិងការធំ។
- អ្នកបម្រើ គឺជាអ្នកដែលចេះឲ្យ មិនត្រឹមតែពេលវេលា កម្លាំង និងទឹកចិត្តប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រាក់កាក់ និងសម្ភារៈរបស់គាត់ទៀតផង។ អ្នកជឿម្នាក់ៗគួរតែមានផែនការមួយផ្ទាល់ខ្លួនក្នុងការផ្ដល់ប្រាក់កាក់ដោយយោងទៅតាមគោលការណ៍នៃបទគម្ពីរ។

# ការចូលឲ្យបានស៊ីជម្រៅ

ព្រះជាម្ចាស់បានប្រទានអំណោយទានខាងវិញ្ញាណដល់យើង ដើម្បីបម្រើអ្នកដទៃដោយក្តីស្រឡាញ់។ សូមអានពីអំណោយទានទាំងនោះនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១២ និង រ៉ូម ១២:៤-៨។ តើក្នុងចំណោមអំណោយទានទាំងអស់នេះ លោកអ្នកមានអំណោយមួយណាដែរ? តើឥឡូវនេះ លោកអ្នកកំពុងតែប្រើប្រាស់អំណោយទានដែរឬទេ? ប្រសិនបើមិនទាន់បានប្រើប្រាស់ទេនោះ តើលោកអ្នកគួរប្រើប្រាស់អំណោយទាននោះ ដើម្បីបម្រើអ្នកដទៃបានដោយរបៀបណា?

> *ការត្រាស់ហៅយើងឲ្យបន្ទាបខ្លួនគឺជាការត្រាស់ហៅឲ្យយើងបម្រើព្រះជាម្ចាស់ដោយប្រុងស្មារតី ថែមទាំងដឹងច្បាស់ពីអំណោយទាន និងកម្រិតរបស់យើង។*
>
> លោក ហ្គោដិន ធី. ស្ម៊ីត (Gordon T. Smith)

## សៀវភៅសិក្សាព្រះគម្ពីរដ៏មានសារៈសំខាន់សម្រាប់អ្នកដើរតាមព្រះគ្រីស្ទនៅក្នុងសតវត្សទី២១



គបស១

**ជីវិតរបស់លោកអ្នកនៅក្នុងព្រះគ្រីស្ទ** 978-0-9890481-0-1

លោកអ្នកនឹងរៀនចេះពីការទទួលសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែលមានចំពោះលោកអ្នក និងរបៀបយកព្រះគ្រីស្ទទុកជាគោលនៃជីវិត ព្រមទាំងការរស់នៅដោយអំណាចចេស្តារបស់ព្រះវិញ្ញាណបរិសុទ្ធ។



គបស២

**អ្នកដើរតាមព្រះយេស៊ូវដែលពេញដោយព្រះវិញ្ញាណ** 978-0-9890481-1-8

លោកអ្នកនឹងរៀនចេះពីអត្ថន័យនៃការពេញដោយព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឲ្យការស្តាប់បង្គាប់ ការសិក្សាព្រះគម្ពីរ ការអធិស្ឋាន ការប្រកបគ្នា និងការធ្វើបន្ទាល់ ក្លាយទៅជាទម្លាប់ និងមានន័យពេញលេញនៅក្នុងជីវិតរស់នៅរបស់លោកអ្នក។



គបស៤

**អត្តចរិតរបស់អ្នកដើរតាមព្រះយេស៊ូវ** 978-0-9890481-3-2

សៀវភៅដ៏ងាយស្រួលយល់នេះនឹងជួយឲ្យលោកអ្នកយកទៅអនុវត្តលើគុណសម្បត្តិ និងគុណតម្លៃនៃភាពជាសិស្សរបស់ព្រះគ្រីស្ទក្នុងការរស់នៅ។



គបស៥

**មូលដ្ឋានគ្រឹះនៃជំនឿ** 978-0-9890481-4-9

សៀវភៅនៃការសិក្សាព្រះគម្ពីរនេះនឹងជួយលោកអ្នកឲ្យយល់ពីព្រះជាម្ចាស់ ព្រះបន្ទូលរបស់ទ្រង់ ព្រះវិញ្ញាណបរិសុទ្ធ និងការតយុទ្ធខាងព្រលឹងវិញ្ញាណ ព្រមទាំងការយាងមកវិញរបស់ព្រះគ្រីស្ទ។



គបស៦

**ការរីកចម្រើនក្នុងភាពជាសិស្សរបស់ព្រះយេស៊ូវ** 978-0-9890481-5-6

ការសិក្សាព្រះគម្ពីរពីសៀវភៅនេះនឹងផ្តល់នូវការយល់ដឹងដ៏ជ្រៅជ្រះ ព្រមទាំងការលើកទឹកចិត្ត ដើម្បីជួយឲ្យលោកអ្នកមានការលូតលាស់ក្នុងនាមជាសិស្សដ៏ពិតរបស់ព្រះគ្រីស្ទតាមរយៈការចែកចាយព្រះពរដល់អ្នកដទៃដែលព្រះជាម្ចាស់បានប្រទានមកលោកអ្នក។



គបស៧

**សេចក្តីសង្ឃឹមរបស់យើងនៅក្នុងព្រះគ្រីស្ទ** 978-0-9890481-6-3

សៀវភៅនៃការសិក្សាកណ្ឌគម្ពីរ ១ថែស្សាឡូនីចនេះ នឹងផ្តល់ជាគំរូដល់លោកអ្នកក្នុងការសិក្សាកណ្ឌគម្ពីរផ្សេងទៀតក្នុងព្រះគម្ពីរ ហើយលោកអ្នកនឹងទទួលបានគោលការណ៍នៃការសិក្សាព្រះគម្ពីរដ៏មានឥទ្ធិពលដែលលោកអ្នកអាចប្រើប្រាស់បានពេញមួយជីវិត។



**គបស សៀវភៅសម្រាប់គ្រូ** 978-0-9890481-7-0

សៀវភៅនេះនឹងផ្តល់នូវការយល់ដឹងដ៏ជ្រៅជ្រះដល់គ្រូបង្រៀន និងព័ត៌មានផ្សេងៗដែលគ្រូបង្រៀនត្រូវដឹង ដើម្បីបង្រៀនពីចំណុចសំខាន់នៃភាពជាសិស្សដ៏ពិតជាមួយអ្នកផ្សេងទៀត ទោះបីជាត្រូវបង្រៀនម្នាក់ទល់ម្នាក់ ឬក៏បង្រៀនជាក្រុម។

NAVPRESS
Discipleship Inside Out®

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ
For purchase information please visit
www.cambodianchristianresources.com/dfd